ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ផែនការយុទ្ធសាស្ត្រថវិកា
# ឆ្នាំ២០២៦ - ២០២៨

ខែកក្កដា ឆ្នាំ ២០២៥

# មាតិកា


**I. សេចក្តីផ្តើម** .......... ១

១. ចក្ខុវិស័យ បេសកកម្ម និងភារកិច្ចចម្បងៗ របស់ក្រសួង .......... ១

២. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤ និងវឌ្ឍនភាពនៃសូចនាករគន្លឹះ .......... ៣

៣. បញ្ហាប្រឈម .......... ១០

៤. វិធានការគោលនយោបាយសម្រាប់រួមចំណែកអនុវត្តអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល .......... ២១

**II. គោលបំណងគោលនយោបាយ** .......... ២២

**III. ការរៀបចំកម្មវិធី** .......... ២៤

**IV. ការកំណត់រចនាសម្ព័ន្ធថវិកាសមិទ្ធកម្ម** .......... ៣៩

**V. ការកំណត់ធនធាន** .......... ១៣៧

**VI. សេចក្តីសន្និដ្ឋាន** .......... ១៧១

## I. សេចក្តីផ្តើម

ក្រសួងអប់រំ យុវជន និងកីឡានៅតែបន្តធ្វើការងារយ៉ាងសកម្ម និងបានក្លាយទៅជាទម្លាប់នៃការអនុវត្តកំណែទម្រង់យុទ្ធសាស្ត្រវិស័យអប់រំឥតឈប់ឈរ ឆ្ពោះទៅមុខជានិច្ចប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ស្តីពី ការអភិវឌ្ឍមូលធនមនុស្ស ក្នុងនោះការពង្រឹងគុណភាពវិស័យអប់រំ យុវជន និងកីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ការលើកកម្ពស់ការស្រាវជ្រាវនិងនវានុវត្តន៍ការលើកកម្ពស់សេវាសាធារណៈ និងអាហារូបត្ថម្ភ និងការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម។

ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ ដែលត្រូវបានអនុវត្តជាបួនដំណាក់កាលបន្តបន្ទាប់៖ (១)កំណែទម្រង់ថ្នាក់ជាតិ ឆ្នាំ២០១៤ (២)កំណែទម្រង់ផ្តោតលើសសរស្តម្ភ៥ ឆ្នាំ២០១៥-២០១៨ (៣)កំណែទម្រង់សាលារៀនឆ្នាំ២០១៩-២០២២ និង (៤)ការអនុវត្តស្តង់ដាសាលារៀនគំរូឆ្នាំ២០២៣-បច្ចុប្បន្ន។ ក្រសួងនៅតែបន្តឈរលើមូលដ្ឋានគ្រឹះរឹងមាំដោយមានកិច្ចសហការពីដៃគូអភិវឌ្ឍន៍ដើម្បីអភិវឌ្ឍវិស័យអប់រំរបស់ខ្លួន ក្នុងការផ្តល់សេវាអប់រំមូលដ្ឋានប្រកបដោយសមធម៌បរិយាបន្ន និងមានគុណភាពខ្ពស់ក្នុងការឈានទៅសម្រេចវត្ថុបំណងគោលនយោបាយអប់រំ។ ក្រសួងបានដាក់ចេញនូវអាទិភាពគន្លឹះចំនួន៨ សម្រាប់វិស័យអប់រំ យុវជន និងកីឡា នៅក្នុងសន្និបាតអប់រំ ចាប់តាំងពីឆ្នាំសិក្សា ២០២២-២០២៣ និងឆ្នាំបន្តបន្ទាប់ រហូតមកដល់បច្ចុប្បន្ន ដោយផ្តោតលើ៖ (១)ការពង្រឹងអភិបាលកិច្ចសាលារៀន (២)ការពិនិត្យនិងកែសម្រួលកម្មវិធីសិក្សា និងសកម្មភាពបន្ថែមក្រៅម៉ោងសិក្សាស្របតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងអាកប្បកិរិយារបស់សិស្ស (៣)ការថែរក្សាសុខភាពសិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភរបស់កុមារ និងការគ្រប់គ្រងគុណភាពអាហារនៅតាមសាលារៀន (៤)ការជំរុញនិងលើកទឹកចិត្តឱ្យមានការចូលរួមពីមាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងវិស័យអប់រំ ស្របតាមពាក្យស្លោកភាពជាដៃគូរវាង និងសហគមន៍ក្នុងការអប់រំ (៥)ការពង្រឹងការអប់រំឌីជីថល (៦)ការជំរុញមជ្ឈមណ្ឌលឧត្តមភាពក្នុងការអប់រំឧត្តមសិក្សា (៧) ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព និង (៨)ការអភិវឌ្ឍការអប់រំកាយ និងកីឡា។

## ១. ចក្ខុវិស័យ បេសកកម្ម និងភារកិច្ចចម្បងៗ របស់ក្រសួង

ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់នូវចក្ខុវិស័យ គឺប្រជាជនកម្ពុជា **«មានចំណេះដឹងខ្ពស់ និងជំនាញមួយយ៉ាងតិចប្រចាំជីវិត»** ប្រកបដោយអំណត់ធន់ សហគ្រិនភាព នវានុវត្តន៍ និងសីលធម៌ប្រពៃ ដោយវឌ្ឍជានាផ្តល់សេវាអប់រំជាមូលដ្ឋានសម្រាប់ទាំងអស់គ្នាយ៉ាងតិចត្រឹមថ្នាក់ទី៩ បំពាក់ជំនាញ និងបច្ចេកវិទ្យាដែលជាតម្រូវការទីផ្សារការងារ និងធុរកិច្ច ពង្រឹងការបណ្តុះបណ្តាល និងផ្លាស់ប្តូរជំនាញ ស្របនឹងតម្រូវការទីផ្សារការងារ ពង្រឹងគុណភាពវិស័យឧត្តមសិក្សាឱ្យក្លាយជាមណ្ឌលមូលធនបញ្ញាជាតិ និងឃ្លាំងពុទ្ធិសកល និងយកចិត្តទុកដាក់លើជីវភាពគ្រូបង្រៀន បុគ្គលិកសិក្សា និងសាស្ត្រាចារ្យ។

ដើម្បីសម្រេចបានតាមចក្ខុវិស័យខាងលើ ក្រសួងអប់រំ យុវជន និងកីឡា មានបេសកកម្មធ្វើបរិវត្តកម្មប្រព័ន្ធអប់រំឆ្ពោះទៅរកការអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន ភាពពាក់ព័ន្ធ និងភាពធន់ ដើម្បីដោះស្រាយបញ្ហាការសិក្សា និងកសាងសង្គមប្រកបដោយសមធម៌ បរិយាបន្ន ចីរភាព និងសង្គមផ្អែកលើពុទ្ធិ ស្របតាមបំណងប្រាថ្នាប្រទេសកម្ពុជា។

វត្ថុបំណងរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺអភិវឌ្ឍន៍យុវជនកម្ពុជាលើគ្រប់វិស័យ និងបណ្តុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូបឱ្យមានមោទនភាពជាតិ មានសីលធម៌ល្អ និងគុណធម៌ខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន។

វត្ថុបំណងចំពោះមុខរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺធានាថាយុវជន និងកុមារកម្ពុជាគ្រប់រូប មានឱកាសស្មើគ្នា ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមវេជ្ជមនុញ្ញ និងការប្តេជ្ញាចិត្ត របស់រាជរដ្ឋាភិបាល ចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ពោលគឺគោលការណ៍មិន រើសអើងអំពីស្ថានភាពសង្គម ភូមិសាស្រ្ត ជនជាតិ សាសនា ភាសា ភេទ និងកាយសម្បទា។ ក្រសួង សង្ឃឹម ទុកថានៅពេលដែលសិស្ស និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួន ពួកគេនឹងមានចំណេះដឹងស្របតាមស្តង់ដា មួយសមស្រប ព្រមទាំងអាចប្រកួតប្រជែងនៅលើទីផ្សារការងារក្នុងតំបន់ និងលើសកលលោក និងអាច ក្លាយជាកម្លាំងស្នូល សម្រាប់ជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ។

ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ ខ្ពស់ជាអាទិ៍៖ (i)កំណត់គោលនយោបាយអប់រំ យុវជន និងកីឡាសំដៅការអភិវឌ្ឍធនធានមនុស្សប្រកបដោយ ចីរភាព (ii)កសាងនីតិក្រមសម្រាប់អភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា (iii)កសាងផែនការអនុវត្តពិនិត្យ តាមដាន និងវាយតម្លៃគោលនយោបាយអប់រំ យុវជន និងកីឡា ដើម្បីអភិវឌ្ឍធនធានមនុស្ស ព្រមទាំងលើក ទិសដៅ និងវិធានការកែលម្អជាបន្តបន្ទាប់តាមមុខជំនាញ (iv)លើកកម្ពស់គុណភាពវិស័យអប់រំ យុវជន និង កីឡាឱ្យឆ្លើយតបទៅនឹងដំណាក់កាលនីមួយៗនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ និងអន្តរជាតិ ដើម្បីកសាង សមត្ថភាពខាងចំណេះដឹង និងចំណេះធ្វើ សីលធម៌ និងចេះរួមរស់ជាមួយគ្នា (v)តម្រង់ទិសវិជ្ជាជីវៈ បំណិន ជីវិត និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅគ្រប់ភូមិសិក្សា (vi)លើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ ទាំងអស់គ្នាដោយធានាសមធម៌ និងបរិយាបន្ន (vii)អភិវឌ្ឍន៍ធនធានមនុស្សលើផ្នែកបច្ចេកទេស សហគ្រិនភាព និងអប់រំបច្ចេកទេសក្នុងតំបន់ (viii)សិក្សាសំណើបង្កើត បើក បិទ បញ្ចូលគ្នា ជំនាញថ្មី បំបែក ប្រែក្លាយគ្រឹះស្ថាន ឧត្តមសិក្សាសាធារណៈ (ix) សិក្សាលើសំណើទទួលស្គាល់ការបង្កើត បើក បិទ បញ្ចូលគ្នា ជំនាញថ្មី បំបែក ប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាឯកជន (x)លើកកម្ពស់ការស្រាវជ្រាវ និងបច្ចេកវិទ្យាព័ត៌មាន ដើម្បី អភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា (xi)គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃដំណើរការសិក្សា ការនិពន្ធ ការផ្សាយ ការនាំចូលសៀវភៅសិក្សា និងឯកសារពាក់ព័ន្ធនឹងការបង្រៀន និងរៀននៅគ្រប់កម្រិតសិក្សា គ្រប់ភូមិសិក្សា និងដាក់ពិន័យ (xii)អភិវឌ្ឍការងារយុវជន និងការងារអប់រំកាយ និងកីឡា ដោយកំណត់វិធានការគ្រប់គ្រង បណ្តុះបណ្តាល និងបំប៉នបច្ចេកទេស (xiii)បង្កើនការយល់ដឹងវប្បធម៌ជាតិ និងវប្បធម៌អន្តរជាតិ (xiv)គ្រប់គ្រង បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា (xv)ពិនិត្យនិងផ្តល់យោបល់គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងវិស័យ អប់រំ យុវជន និងកីឡា (xvi)ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារតាមកាលកំណត់ជូនរាជរដ្ឋាភិបាល និង (xvii)ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ការលើកកម្ពស់គុណភាពការអប់រំត្រូវផ្តោតលើការលើកកម្ពស់គុណភាពរបស់ធាតុចូល ដំណើរការ រៀននិងបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស។ គុណភាពរបស់ធាតុចូលនឹងផ្តោតសំខាន់លើគុណវុឌ្ឍិ

គ្រូបង្រៀន ដែលបានត្រូវបង្កើនរូបមន្តពី ១២ បូក ២ ទៅដល់ ១២ បូក ៤ នៅឆ្នាំ២០៣០។ គុណភាពកម្មវិធីសិក្សានៅអប់រំចំណេះទូទៅ និងឧត្តមសិក្សា ឱ្យស្របនឹងគុណភាពស្តង់ដាអាស៊ាន។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨ បានកំណត់វិធានការកែលម្អការគ្រប់គ្រងថវិកាឱ្យមានប្រសិទ្ធភាពក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងលទ្ធផលការងារ និងការបែងចែកធនធានហិរញ្ញវត្ថុសាធារណៈប្រកបដោយសមធម៌ តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ជាពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបច្ចុប្បន្ន ដល់ដំណាក់កាលទី៤ ដើម្បីពង្រឹងមូលដ្ឋានគ្រឹះនៃការកែទម្រង់ក្នុងខឿនទាំង៣ ខាងដើម មុនឈានទៅអនុវត្តខឿនទី៤ "គណនេយ្យភាពសមិទ្ធកម្ម" ។ ដំណាក់កាលអន្តរកាល ឆ្ពោះទៅខឿនទី៤ មានគោលដៅក្នុងការកសាងលក្ខខណ្ឌចាំបាច់នានា ដើម្បីឈានទៅដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ដែលជាគន្លឹះក្នុងការកសាង " វប្បធម៌សមិទ្ធកម្ម"។

ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំនេះ បានគាំទ្រដោយផែនការយុទ្ធសាស្ត្រថវិការយៈពេល ៣ឆ្នាំរំកិល ថវិកាកម្មវិធីប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ។ តាមការធ្វើចំណោលលើគម្រោងចំណាយថវិកាកម្មវិធីសម្រាប់ឆ្នាំ២០២៦ មានចំនួន ៤ ២៥៦ ២៤៨,១លានរៀល ធៀបនឹងឆ្នាំ២០២៥ កើនឡើង ៤,១៦ភាគរយ ហើយឆ្នាំ២០២៧ ចំនួន ៤ ២៥៣ ៩០០,២លានរៀល ធៀបនឹងឆ្នាំ២០២៦ ថយចុះ ០,០៦ភាគរយ និងឆ្នាំ២០២៨ ចំនួន ៤ ៣៣៩ ២៥៤,៣លានរៀល ធៀបនឹងឆ្នាំ២០២៧ កើនឡើង ៣,៤២ភាគរយ។

## ២. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៤ និងវឌ្ឍនភាពនៃសូចនាករគន្លឹះ

### ២.១ វឌ្ឍនភាពនៃការសម្រេចបានសូចនាករសមិទ្ធកម្មគន្លឹះ

ដើម្បីរួមចំណែកកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់សូចនាករសមិទ្ធកម្មគន្លឹះ (KPIs) សម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ រួមមាន៖ ១). លទ្ធផលនៃកម្មវិធីវាយតម្លៃសិស្សជាអន្តរជាតិ PISA ២). អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ និងអត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ និង ៣). អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ និងអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ។ ជាលទ្ធផលក្នុងឆ្នាំ២០២៤ វឌ្ឍនភាពនៃការសម្រេចបានសូចនាករសមិទ្ធកម្មគន្លឹះយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ មានដូចខាងក្រោម៖

១). លទ្ធផលនៃកម្មវិធីវាយតម្លៃសិស្សជាអន្តរជាតិ (PISA) មិនត្រូវបានធ្វើការវាយតម្លៃទេ នៅក្នុងឆ្នាំ២០២៤ ដោយកម្មវិធីនេះត្រូវអនុវត្តនៅឆមាសទី២ ឆ្នាំ២០២៥ និងឆ្នាំ២០២៩ និងផ្តោតសំខាន់ទៅលើពិន្ទុជាមធ្យមនៃមុខវិជ្ជាចំនួន៣ រួមមានអំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រ។

២). អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ សម្រេចបានលើសចំណុចដៅ គឺ ៧៥,២ភាគរយ និងអត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិសម្រេចបានទាបជាងចំណុចដៅ ៤៤,៣ភាគរយ ប៉ុន្តែអាចទទួលយកបាន ដោយវឌ្ឍនភាពប្រហាក់ប្រហែលឆ្នាំកន្លងទៅ។

៣). អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ សម្រេចបាន ១៥,៥ភាគរយ លើសចំណុចដៅ និងអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ សម្រេចបាន ១៣,៧ភាគរយ លើសចំណុចដៅ។

ទន្ទឹមនេះ ក្រសួងក៏បានរៀបចំសូចនាករអប់រំគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលបានដាក់ចេញសកម្មភាពជាក់លាក់ ដោយបន្សីជាមួយនឹងអាទិភាពកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា និងបានចុះកិច្ចព្រមព្រៀងសមិទ្ធកម្មលើការអនុវត្តថវិកាប្រចាំឆ្នាំ២០២៤ ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាឆ្នាំទី២ ក្នុងគោលបំណងលើកកម្ពស់ការចូលរួមអនុវត្តប្រព័ន្ធព័ត៌មានថវិកាសមិទ្ធកម្ម ឬ "ថវិកាសមិទ្ធកម្ម" ក្នុងស្មារតីតម្រូវឱ្យមានការវាស់វែងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តកម្មវិធី តាមរយៈសូចនាករសមិទ្ធកម្ម ដោយផ្សារភ្ជាប់លទ្ធផលក្នុងឆ្នាំ និងអាទិភាពគោលនយោបាយ សម្រាប់ធ្វើសេចក្តីសម្រេចចិត្តលើការវិភាជថវិកា ឬធនធានហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។ ក្នុងកិច្ចព្រមព្រៀងសមិទ្ធកម្មនេះ ក្រសួងអប់រំ យុវជន និងកីឡា បានយល់ព្រមលើការអនុវត្តកម្មវិធីចំនួន ០៥ មានទឹកប្រាក់សរុបចំនួន ៤២០ ៤២៥,៤លានរៀល (ថ្នាក់កណ្តាល) ដោយមានសូចនាករសមិទ្ធកម្មគន្លឹះចំនួន១១ សម្រាប់វាស់វែងលទ្ធផលការងាររបស់ក្រសួង។

ជាលទ្ធផល ក្នុងឆ្នាំ២០២៤ ក្រសួងអប់រំ យុវជន និងកីឡា សម្រេចបាន ១០០ភាគរយ ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ក្នុងផែនការប្រចាំឆ្នាំ ព្រមទាំងឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃកំណែទម្រង់សំខាន់ៗ និងវឌ្ឍនភាព ដូចខាងក្រោម ៖

**កម្មវិធីទី១៖ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ**

កម្មវិធីទី១ មានអនុកម្មវិធីចំនួន ១០ សម្រេចបាន ១០០ភាគរយ ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ ក្នុងនោះ សមិទ្ធកម្មគន្លឹះសំខាន់ៗ រួមមាន៖

- សាលារៀនគំរូ សម្រេចបាន ២៥០សាលា
- សិស្សថ្នាក់ទី១២ ទទួលបាន និទ្ទេស A, B, និង C សម្រេចបាន ២៥,៧ភាគរយ។

**កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ**

កម្មវិធីទី២ មានអនុកម្មវិធីចំនួន ១៨ សម្រេចបាន ១០០ភាគរយ ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ ក្នុងនោះ សមិទ្ធកម្មគន្លឹះសំខាន់ៗ រួមមាន៖

- អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (អាយុ ១៨-២២) សម្រេចបាន ១៩,១ភាគរយ
- លទ្ធផលស្រាវជ្រាវចំនួន ២២ ដែលភ្ជាប់ជាមួយនឹងតម្រូវការទីផ្សារ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមដែលប្រើប្រាស់ដោយ HEIs និងឧស្សាហកម្ម។

**កម្មវិធី៣៖ ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា**

កម្មវិធីទី៣ មានអនុកម្មវិធីចំនួន ៨ សម្រេចបាន ១០០ភាគរយ ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ ក្នុងនោះ សមិទ្ធកម្មគន្លឹះសំខាន់ៗ រួមមាន៖

- មេដាយពីការប្រកួតកីឡាអន្តរជាតិ ទទួលបាន ២៣៧មេដាយ
- សាលារៀន ១៨០សាលា បានអនុវត្តកម្មវិធីអប់រំកាយ និងកីឡា។

**កម្មវិធីទី៤៖ ការអភិវឌ្ឍយុវជន**

កម្មវិធីទី៤ មានអនុកម្មវិធីចំនួន ៤ សម្រេចបាន ១០០% ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ ក្នុងនោះ សមិទ្ធកម្មគន្លឹះសំខាន់ៗ រួមមាន៖

- កុមារ និងយុវជនចំនួន ១ ១៦៨នាក់ បានបញ្ចប់កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋាន
- យុវជន និងមនុស្សពេញវ័យចំនួន ១ ៧២៧នាក់ បានបញ្ចប់កម្មវិធីអភិវឌ្ឍន៍យុវជន និងមនុស្សពេញវ័យ។

**កម្មវិធីទី៥៖ ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ**

កម្មវិធីទី៥ មានអនុកម្មវិធីចំនួន ១៨ សម្រេចបាន ១០០% ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ ក្នុងនោះ សមិទ្ធកម្មគន្លឹះសំខាន់ៗ រួមមាន៖

- ភាគរយនៃការទូទាត់ចំណាយថវិកាកម្មវិធីរបស់ក្រសួង សម្រេចបាន ៩៥,៩៥ភាគរយ
- សាលារៀនចំនួន ២៥០សាលា បានអនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រង
- អ្នកឯកទេសអប់រំចំនួន ៤១៦នាក់ បានបណ្តុះបណ្តាល និងទទួលស្គាល់។

## ២.២ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា

### ២.២.១ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ

- ក្រសួងបានរៀបចំរចនាសម្ព័ន្ធថ្មីនៃការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន ដើម្បីឆ្លើយតបនឹងអនុក្រឹត្យលេខ ១០១ អនក្រ.បក ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងបានពិនិត្យលើវិសេសភាព និងមុខងាររបស់អង្គភាព ដើម្បីរៀបចំបញ្ជីមុខតំណែងវិជ្ជាជីវៈមន្ត្រីអប់រំ ដើម្បីគាំទ្រលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការជ្រើសរើស និងការគ្រប់គ្រងមន្ត្រីតាមកិច្ចព្រមព្រៀង ការកំណត់មុខតំណែង និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈអប់រំ មានចំនួនសរុប ៣៣២ មុខតំណែង
- បុគ្គលិកអប់រំគ្រប់កម្រិតមាន ១២៦ ៧៦៦នាក់ ស្រី ៤៨ភាគរយ (ថ្នាក់ជាតិ ៥ ២៤២នាក់ ស្រី ៣៥,១ភាគរយ និងថ្នាក់ក្រោមជាតិ ១២១ ៥២៤នាក់ ស្រី ៤៨,២ភាគរយ)
- ទទួលស្គាល់នាយកសាលាល្អចំនួន ១០នាក់ ស្រី ២នាក់ គ្រូបង្រៀនល្អ ១០នាក់ ស្រី ៣នាក់ គ្រូបង្រៀនល្អភាសាខ្មែរថ្នាក់ទី១ ទី២ និងទី៣ ចំនួន ១០នាក់ ស្រី ៧នាក់ គ្រូបង្រៀនល្អគណិតវិទ្យាថ្នាក់ទី១ ទី២ និងទី៣ ចំនួន ១០នាក់ ស្រី ៨នាក់ និងសាលាស្អាតចំនួន ១០ (បឋមសិក្សា ២ និងវិទ្យាល័យ ៨)។

### ២.២.២ វឌ្ឍនភាពនៃការងារគោលនយោបាយ និងផែនការ

- អនុម័តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀនឆ្នាំ២០២៤-២០៣៥
- អនុម័ត និងដាក់ប្រើប្រាស់ផែនការយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន
- រៀបចំសូចនាករសមិទ្ធកម្មគន្លឹះ និងសូចនាករគាំទ្រការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់-កាលទី១
- អនុម័ត និងផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨
- រៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មកម្រិត១ និងកម្រិត២
- រៀបចំសកម្មភាពអាទិភាពឆ្នាំ២០២៥ របស់ក្រសួងអប់រំ យុវជន និងកីឡា

- កែលម្អ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ (តាមអនឡាញ) សម្រាប់ការបញ្ចូលទិន្នន័យអប់រំដោយផ្ទាល់ពីសាលារៀន
- រៀបចំក្របខណ្ឌការងារ និងទម្រង់របាយការណ៍សន្និបាតថ្នាក់ជាតិ និងរាជធានី ខេត្ត ឆ្នាំ២០២៥
- រៀបចំសេចក្តីព្រាងក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្មវិស័យអប់រំ យុវជន និងកីឡា។

**២.២.៣ វឌ្ឍនភាពនៃការអនុវត្តហិរញ្ញប្បទានសហប្រតិបត្តិការ**

- គម្រោងអភិវឌ្ឍនវិស័យអប់រំនៅមធ្យមសិក្សាទុតិយភូមិទី២ (USESDP 2) ថវិកាសរុប ៣៨,៥ លានដុល្លារអាមេរិក (ខែធ្នូ ឆ្នាំ២០១៨ ដល់ខែមិថុនា ឆ្នាំ២០២៥) ផ្តោតលើ៖ ១). បង្កើនលទ្ធភាពទទួលបានការអប់រំនៅមធ្យមសិក្សាទុតិយភូមិ ២). បង្កើនគុណភាព និងការឆ្លើយតបទីផ្សារការងារនៃការអប់រំមធ្យមសិក្សាទុតិយភូមិ និង៣). ពង្រឹងសមត្ថភាពស្ថាប័នក្នុងការរៀបចំផែនការគ្រប់គ្រង និងផ្តល់សេវាអប់រំ។ ជាលទ្ធផលសំខាន់ៗ រួមមាន ការអភិវឌ្ឍវិទ្យាស្ថានជាតិអប់រំ បំប៉នគ្រូស្ទែម (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា) អភិវឌ្ឍសម្ភាររូបវន្ត (វិទ្យាល័យធនធាន ៣៦ និងវិទ្យាល័យបណ្តាញ ៨៧) អភិវឌ្ឍការសិក្សាបំណិនជីវិត និងជំនាញ (បង្កើតកម្មវិធីមគ្គុទ្ទេសក៍អាជីព កម្មវិធីត្រីវិស័យ កម្មវិធីសិក្សាបន្ថែមបំណិនស្ទែម ការបង្កើតភាពជាដៃគូវិទ្យាល័យ-ឧស្សាហកម្ម)។ ក្រៅពីនេះ បានធ្វើការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំលើស្តង់ដាសាលារៀនគំរូ ការប្រឹក្សាយោបល់ ការរៀបចំនិងដំណើរការប្រឡង និងប្រព័ន្ធអធិការកិច្ចតំបន់ថ្មី
- មូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំដំណាក់កាលទី៥ (GPE5) ថវិកាសរុប ២,៧លានដុល្លាអាមេរិក (ឆ្នាំ២០២៤ ដល់ ២០២៦) ផ្តោតលើ៖ ១). ការអប់រំគ្រូបង្រៀន ២). ការអភិវឌ្ឍអាជីពគ្រូបង្រៀន ៣). ការសិក្សាក្នុងថ្នាក់រៀន និង៤). បរិវត្តកម្មឌីជីថលក្នុងវិស័យអប់រំ។ ជាលទ្ធផលសំខាន់ៗ រួមមាន ការបណ្តុះបណ្តាលគណៈគ្រប់គ្រងនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងពិនិត្យតាមដាននិងវាយតម្លៃ ការអភិវឌ្ឍសម្ភារឧទ្ទេស និងផែនការសកម្មភាព ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យសិស្ស អំណានថ្នាក់ដំបូងថ្នាក់ទី១ និងទី២ រួមទាំងការចែកសៀវភៅណែនាំ និងសម្ភារឧបទេស សម្រាប់កម្មវិធីអំណានថ្នាក់ដំបូងថ្នាក់ទី១ និងទី២
- គម្រោងកែលម្អការអប់រំឧត្តមសិក្សា (HEIP) ថវិកាសរុប ៩២,៥លានដុល្លាអាមេរិក (ឆ្នាំ២០១៨ ដល់ ២០២៤) ផ្តោតលើ ការកែលម្អគុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា និងការស្រាវជ្រាវ ជាពិសេសផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) និងកសិកម្មនៅតាមគ្រឹះស្ថានឧត្តមសិក្សាគោលដៅ និងកែលម្អប្រព័ន្ធអភិបាលកិច្ចនៃអនុវិស័យឧត្តមសិក្សា។ ជាលទ្ធផលសំខាន់ៗ រួមមាន កម្មវិធីអប់រំបង្កើតថ្មី និងកែលម្អ ៦៧ បានទទួលការវាយតម្លៃពីអ្នកជំនាញការអន្តរជាតិ បន្ទប់ពិសោធន៍ ១៦៧ បានសាងសង់និងជួសជុល ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការរៀននិងបង្រៀន ។ សាងសង់អគារមជ្ឈមណ្ឌលស្រាវជ្រាវបណ្តុះបណ្តាលកសិកម្ម អគារស្ទែម និងអគារបណ្តុះធុរកិច្ច សម្រេចបាន ១០០ភាគរយ។ សាងសង់អគារសិក្សា និងអន្តេវាសិកដ្ឋាន សម្រេចបាន ៤០ភាគរយ។ ជាមួយគ្នានេះ គម្រោងស្រាវជ្រាវ

៥២ ក្នុងចំណោម ៥៣ បានបញ្ចប់ និងរបាយការណ៍បញ្ចប់ការស្រាវជ្រាវរបស់គម្រោងនីមួយៗ បានរៀបចំរួចរាល់

- គម្រោងការគ្រប់គ្រងទិន្នន័យអប់រំនៅមធ្យមសិក្សាប្រកបដោយប្រសិទ្ធភាពដើម្បីជួយដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា និងប្រទេសក្នុងតំបន់ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង (មេគង្គឡានឆាង) ថវិកាសរុប ៤៥៨ ៥០០ដុល្លាអាមេរិក (ឆ្នាំ២០២៣ និង២០២៤) ផ្តោតលើការកសាង និងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យអប់រំ ប្រកបដោយប្រសិទ្ធភាព ឆ្លើយតបទៅនឹងតម្រូវការស្តង់ដាជាតិ តំបន់ និងចែករំលែកនូវឧត្តមានុវត្តន៍ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យអប់រំនៅមធ្យមសិក្សាចំណេះទូទៅ។ ជាលទ្ធផលសំខាន់ៗ គឺការវិភាគស្ថានភាពលើប្រព័ន្ធគ្រប់គ្រងទិន្នន័យ
- គម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំកម្រិតមធ្យមសិក្សា (STEP UP) ថវិកាសរុប ៧៨,២៤លានដុល្លាអាមេរិក (ឆ្នាំ២០២៣ ដល់ ២០២៩) ផ្តោតលើ៖ ១). ការទទួលបានសមធម៌ក្នុងការពង្រីកការអប់រំផ្អែកលើស្តង់ដានៅមធ្យមសិក្សាទុតិយភូមិ ២). ពង្រឹងការបង្រៀននិងរៀនស្ទែម និង៣). ពង្រឹងសមត្ថភាពស្ថាប័នក្នុងការរៀបចំផែនការ ការគ្រប់គ្រង និងផ្តល់សេវាអប់រំ។ ជាលទ្ធផលសំខាន់ៗ រួមមាន ការអភិវឌ្ឍសម្ភារូបវន្តសាលារៀន កែលម្អកន្លែងលាងដៃក្នុងវិទ្យាល័យធនធាន បញ្ចប់ការសិក្សាដំបូងនិងសេចក្តីព្រាងរបាយការណ៍ចុងក្រោយនៃការបង្កើតមជ្ឈមណ្ឌលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកម្ពុជា (CSTC) នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ការបញ្ចប់កម្មវិធីសិក្សាលម្អិតនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់គ្រូស្ទែម កែសម្រួលសៀវភៅណែនាំការពិសោធន៍វិទ្យាសាស្ត្រ (មុខវិជ្ជារូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា) ផលិតសៀវភៅណែនាំស្តីពីយន្តការសម្រាប់គាំទ្រស្តង់ដាសាលារៀនគំរូ
- គម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ថវិកាសរុប ៧០,២៥លានដុល្លាអាមេរិក (ឆ្នាំ២០២២ ដល់ ២០២៦) ផ្តោតលើ៖ ១). ធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិក្សារបស់សិស្សតាមរយៈការគ្រប់គ្រងសាលារៀន និងការចូលរួមរបស់សហគមន៍ ២). លើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងការបណ្តុះបណ្តាល ៣). ពង្រីកលទ្ធភាពទទួលបានសមធម៌ក្នុងបរិយាកាសប្រកបដោយគុណភាព និង៤). ពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ការធ្វើផែនការ ការត្រួតពិនិត្យ និងការវាយតម្លៃក្នុងវិស័យអប់រំ។ ជាលទ្ធផលសំខាន់ៗ រួមមាន បណ្តុះបណ្តាលស្តីពីយុទ្ធសាស្ត្រសហគមន៍ កម្មវិធីបណ្តុះបណ្តាលបង្កើនសមត្ថភាពបង្រៀនភាសាខ្មែរ និងគណិតវិទ្យា កម្មវិធីបង្កើនគុណវុឌ្ឍិគ្រូបង្រៀន (TUP) កម្មវិធីបង្កើនភាពជាអ្នកដឹកនាំ (LUP) រួមទាំងការផ្តល់ជូនសាលារៀនចំនួន ១៥៤សាលា នូវបន្ទប់រៀន បន្ទប់ពិសោធន៍ និងកន្លែងស្នាក់នៅរបស់គ្រូ សម្រេចបាន ៩៩ភាគរយ
- គម្រោងកសាងសមត្ថភាពបច្ចេកវិទ្យាព័ត៌មានសម្រាប់ការអប់រំមធ្យមសិក្សាបឋមភូមិនៅប្រទេសកម្ពុជា ថវិកាសរុប ៧លានដុល្លាអាមេរិក (ឆ្នាំ២០២១ ដល់ ២០២៦) ផ្តោតលើ៖ ១). ការកែលម្អបរិយាកាសបង្រៀនសម្រាប់គរុនិស្សិត និងគ្រូឧទ្ទេសនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ២). ការអភិវឌ្ឍកម្មវិធីសិក្សាមុខវិជ្ជា ICT និងសម្ភារឧបទេស ៣). កម្មវិធីកសាងសមត្ថភាពគ្រូឧទ្ទេស និងគ្រូតាមសាលារៀនគោលដៅ ៤). ការកែលម្អបរិយាកាសសិក្សាសម្រាប់សិស្ស និងគ្រូនៅតាមសាលារៀនគោលដៅ ៥). ការអភិវឌ្ឍកម្មវិធីសិក្សាមុខវិជ្ជា ICT និងសៀវភៅសិក្សាកម្រិត

មធ្យមសិក្សាបឋមភូមិ និង៦). ការពង្រឹងកម្មវិធីគាំទ្រការអប់រំមុខវិជ្ជា ICT ។ ជាលទ្ធផលសំខាន់ៗ រួមមាន ការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ ICT ជូនគ្រូឧទ្ទេស គ្រូបង្រៀន បោះពុម្ពនិងផ្តល់សៀវភៅមុខវិជ្ជា ICT សម្រាប់សិស្សថ្នាក់ទី៧ សាងសង់បន្ទប់ពិសោធន៍ ICT ចំនួន ៤៨ នៅក្នុងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន ៤ និងសាលារៀនឈានមុខ ICT ចំនួន ២០ និងបង្កើតសៀវភៅសិក្សាគោលមុខវិជ្ជា ICT សម្រាប់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ៩ចំណងជើង ជាភាសាខ្មែរ និងអង់គ្លេស

- គម្រោងពង្រឹងវិទ្យាស្ថានគរុកោសល្យសម្រាប់គុណភាពនៃការអប់រំមូលដ្ឋាន (S-TEC) ថវិកាសរុប ២លានដុល្លាអាមេរិក (ឆ្នាំ២០២៤ ដល់ ២០២៧) ផ្តោតលើ៖ ១). ពង្រឹងសកម្មភាពជាដៃគូរវាងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បាត់ដំបង និងសាលាអនុវត្តន៍នៃវិទ្យាស្ថានទាំងពីរ ២). បង្កើតប្រព័ន្ធសម្រាប់កែលម្អការបង្រៀននៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងខេត្តបាត់ដំបង ដោយប្រើប្រាស់បទពិសោធន៍ជាមួយសាលាអនុវត្តន៍ដោយគ្រូឧទ្ទេសរបស់វិទ្យាស្ថានទាំងពីរ ៣). បង្កើតថ្នាលសម្រាប់ចែករំលែកបទពិសោធន៍របស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងខេត្តបាត់ដំបង ជាមួយសាលាគរុកោសល្យ សាលារៀនបឋមសិក្សា និងសាលារៀនចំណេះទូទៅផ្សេងទៀត និង៤). គ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យថ្មីពីរទៀត បានទទួលការបំប៉ននៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងខេត្តបាត់ដំបង។ ជាលទ្ធផលសំខាន់ៗ រួមមាន ការរៀបចំផែនការកែលម្អមេរៀនក្នុងការបង្រៀន ការបណ្តុះបណ្តាលមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ នៅប្រទេសជប៉ុន ការចូលរួមកម្មវិធី IMPULS-LS Alliance 2024 Lesson Study Immersion និងកម្មវិធីការសិក្សាស្រាវជ្រាវមេរៀននៅប្រទេសជប៉ុន
- មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍន៍សមត្ថភាពដំណាក់កាលទី៣ (CDPF 3) ថវិកាសរុប ៣៧,៩លានដុល្លាអាមេរិក (ឆ្នាំ២០១៨ ដល់ ២០២៦) ផ្តោតលើការពង្រឹងសមត្ថភាពមន្ត្រី និងស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការរៀបចំផែនការ ការពិនិត្យតាមដាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុវត្តគោលនយោបាយ និងគាំទ្រអាទិភាពកំណែទម្រង់ផ្សេងទៀត។ ជាលទ្ធផលសំខាន់ៗ រួមមាន ការពង្រឹងប្រព័ន្ធ ដោយគាំទ្រដល់ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨ យុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន ផែនការសកម្មភាពការអប់រំបរិយាបន្នឆ្នាំ២០២៤-២០២៨ ផែនការសកម្មភាពការអប់រំពហុភាសាឆ្នាំ២០២៤-២០២៨ ការស្រាវជ្រាវលើលទ្ធផលសិក្សារបស់សិស្សកម្រិតបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ ការសិក្សាស្រាវជ្រាវពីកត្តាដែលជះឥទ្ធិពលដល់ការរក្សាសិស្សឱ្យគង់វង្សនៅកម្រិតអប់រំចំណេះទូទៅ ការវាយតម្លៃសមត្ថភាពបុគ្គលិកអប់រំលើផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ការសិក្សាវិសាលភាពនៃការធ្វើសមាហរណកម្មទិន្នន័យអប់រំ និងវាយតម្លៃគុណភាពទិន្នន័យអប់រំ ការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង ការកែលម្អកម្មវិធីសិក្សា និងការបណ្តុះបណ្តាលគ្រូឧទ្ទេសតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ការបំប៉នគ្រូឧទ្ទេស និងគ្រូបង្រៀននៅលើកញ្ចប់អំណាន និងគណិតវិទ្យាថ្នាក់ដំបូង ការអប់រំបរិយាបន្ន និងពហុភាសា។

### ២.២.៤ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់ច្បាប់

- វិសោធនកម្មច្បាប់ ស្ដីពីការអប់រំ
- អនុក្រឹត្យ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា និងការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរអប់រំ យុវជន និងកីឡា
- អនុក្រឹត្យ ស្ដីពីការបង្កើត និងការគ្រប់គ្រងទារកដ្ឋាន
- ប្រកាស ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានអប់រំ អគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកដ្ឋានកីឡា អគ្គនាយកដ្ឋានយុវជន អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកដ្ឋានបណ្ដុះបណ្ដាលនិងវិក្រឹតការ និងនាយកដ្ឋានសវនកម្មផ្ទៃក្នុង
- រៀបចំសេចក្ដីព្រាងព្រះរាជក្រឹត្យ ស្ដីពីលក្ខន្តិកៈដោយឡែកនៃអង្គគ្រូបង្រៀន
- ក្រសួងបានរៀបចំលិខិតបទដ្ឋានគតិយុត្តវិស័យអប់រំចំនួន ២៨ ក្នុងនោះ អនុក្រឹត្យ ៥ ប្រកាស ១៥ សេចក្ដីសម្រេច ៧ និងសេចក្ដីជូនដំណឹង ១
- ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តវិស័យអប់រំ។

### ២.២.៥ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- សហការរៀបចំប្រកាសអន្តរក្រសួង ស្ដីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុ មានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- សិក្សារៀបចំទិន្នន័យដើមគ្រាលើគុណភាពនៃសេវាអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅរាជធានីភ្នំពេញ ខេត្តមណ្ឌលគិរី បន្ទាយមានជ័យ សៀមរាប កំពត និងស្វាយរៀង
- សហការរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី គោលការណ៍ បែបបទ និងនីតិវិធីនៃការអនុវត្តមុខងារវិស័យអប់រំ យុវជន និងកីឡាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

### ២.២.៦ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ឆ្នាំ២០២៤ ក្រសួងបានចំណាយថវិកាកម្មវិធី ដោយបោះផ្សាយអាណត្តិបើកប្រាក់បាន ១ ៩៧៣ ៧៨៨ ២៤០ ៩១៩ រៀល ស្មើ ៩៥,៩៥ភាគរយ ធៀបនឹងច្បាប់ថវិកា ក្នុងនោះរដ្ឋបាលកណ្ដាលអនុវត្តបាន ៨២,២៦ភាគរយ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត អនុវត្តបាន ១០០,៣ភាគរយ
- អភិវឌ្ឍកម្មវិធីទូរសព្ទដៃវៃឆ្លាត សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុនៅតាមគ្រប់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសសាលារៀនសាធារណៈទូទាំងប្រទេស
- អនុវត្តស្វ័យប្រវត្តិកម្មប្រព័ន្ធ FMIS ស្ដីពីអនុវត្តសេចក្ដីណែនាំ សម្រាប់នីតិវិធីអនុវត្តការងារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- រៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មកម្រិត១ រវាងក្រសួងអប់រំ យុវជន និងកីឡាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងកម្រិត២ រវាងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងប្រធានកម្មវិធី សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៤
- ពង្រឹង និងជំរុញការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS) លើមុខងារដែលបានដាក់ឱ្យអនុវត្តជាផ្លូវការ តាមរយៈលិខិតលេខ ៤៣១០ អយក.ហវ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤។

### ២.២.៧ វឌ្ឍនភាពនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំ

- គិតត្រឹមខែមករា ឆ្នាំ២០២៥ សំណង់អគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** មាន ៤ ៥៨២ខ្នង ស្មើនឹង ៣០ ១៣៥បន្ទប់
- ការសាងសង់អគារសិក្សាថ្មី ជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធ ជួសជុលកែលម្អអគារសិក្សា សាងសង់ផ្ទះស្នាក់នៅគ្រូ អគារអន្តេវាសិកដ្ឋាននៅតាមសាកលវិទ្យាល័យ កែលម្អបន្ទប់មុខវិជ្ជា សាងសង់អគារមជ្ឈមណ្ឌលភ្ញាស់វិជ្ជា (Incubation Center) និងនៅគ្រឹះស្ថានសិក្សានានា ត្រូវបានគាំទ្រដោយថវិការដ្ឋ ដៃគូអភិវឌ្ឍន៍ គម្រោងនានា និងសប្បុរជន
- រៀបចំគំនូសប្លង់ជម្រាលជនពិការតាមសាលាធនធានទាំង៥០ និងសាលាបណ្តុះទាំង៨៧ សម្រេច ១០០ភាគរយ និងរៀបចំគំនូសប្លង់វិទ្យាល័យធនធាន៥០ ត្រូវតាមស្តង់ដា សម្រេច ៨៥ ភាគរយ។

## ៣. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផលខាងលើ ក្រសួងអប់រំ យុវជន និងកីឡា ក៏មានបញ្ហាប្រឈមមួយចំនួនចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ ដែលបញ្ហាប្រឈមទាំងនោះមានដូចជា៖

### ៣.១ បញ្ហាប្រឈមរួម

#### ៣.១.១ ការងារគោលនយោបាយ

- តម្រូវការបណ្តុះបណ្តាលបន្ថែមលើជំនាញឌីជីថល និងការស្រាវជ្រាវកម្រិតខ្ពស់
- កង្វះមន្ត្រីឯកទេសតាក់តែងគោលនយោបាយ។

#### ៣.១.២ ការងារផែនការ

- កង្វះមន្ត្រីជំនាញផែនការ និងស្ថិតិនៅថ្នាក់រាជធានី ខេត្ត
- ពុំទាន់បន្សុីគ្នារចនាសម្ព័ន្ធថវិកាកម្មវិធី និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨
- ការសម្របសម្រួល និងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការមិនទាន់គ្រប់ជ្រុងជ្រោយ
- សមត្ថភាពក្នុងការវិភាគបញ្ហាកម្រិតសាលារៀននៅមានកម្រិត។

#### ៣.១.៣ ការងារព័ត៌មាននិងស្ថិតិ

- ប្រព័ន្ធគ្រប់គ្រងទិន្នន័យអប់រំពុំទាន់ឆ្លើយតបនឹងតម្រូវការជាក់ស្តែង
- មន្ត្រីបច្ចេកទេសផ្នែកស្ថិតិអប់រំ និងវិភាគ និងផ្នែក ICT មានសមត្ថភាពពុំទាន់ឆ្លើយតបទៅនឹងទំហំការងារបច្ចុប្បន្ន។

៣.១.៤ ការងារពិនិត្យតាមដាន និងវាយតម្លៃ

- ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្មវិស័យអប់រំ យុវជន និងកីឡា នៅមិនទាន់បញ្ចប់ ដោយការកំណត់សូចនាករ និងចំណុចដៅមិនទាន់ច្បាស់លាស់
- កង្វះមន្ត្រីឯកទេសពិនិត្យតាមដាន និងវាយតម្លៃទាំងថ្នាក់ជាតិ និងក្រោមជាតិ ។

៣.១.៥ ការងារវិមជ្ឈការ និងវិសហមជ្ឈការ

- ការកសាងក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនៅមិនទាន់ឆ្លើយតបនឹងកម្មវិធីកំណែទម្រង់ច្បាប់ និងកំណែទម្រង់ការងារវិមជ្ឈការនិងវិសហមជ្ឈការវិស័យអប់រំ
- ប្រសិទ្ធភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តវិស័យអប់រំនៅមានកម្រិត
- ធនធានសម្រាប់គាំទ្រការងារវិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំនៅមានកម្រិត
- សមត្ថភាពគ្រប់គ្រង និងដោះស្រាយវិវាទបុគ្គលិកអប់រំនៅមានកម្រិត។

៣.១.៦ ការងារគ្រប់គ្រងបុគ្គលិក

- ខ្វះធនធានមនុស្សជំនួសធនធានដែលត្រូវចូលនិវត្តន៍ឆ្នាំបន្តបន្ទាប់តាមការិយាល័យជំនាញ
- មានតម្រូវការធនធានមន្ត្រីជំនាញបច្ចេកទេស ជំនាញការ និងធនធានហិរញ្ញវត្ថុសម្រាប់ធ្វើទំនើបកម្មលើប្រព័ន្ធគ្រប់គ្រងព័ត៌មានបុគ្គលិកអប់រំ ការបំពាក់មុខងារថ្មីសម្រាប់ជំរុញការអភិវឌ្ឍប្រព័ន្ធ ការគ្រប់គ្រងប្រព័ន្ធ និងការថែទាំប្រព័ន្ធ។

៣.១.៧ ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ថវិកាចំណាយចរន្តរបស់ក្រសួង មិនទាន់ឆ្លើយតបទៅនឹងសូចនាករគោលដៅ ២០ភាគរយ នៃចំណាយចរន្តថ្នាក់ជាតិ
- ថវិកាចំណាយក្រៅបន្ទុកបុគ្គលិក មិនទាន់ឆ្លើយតបទៅនឹងសូចនាករគោលដៅយ៉ាងតិច ២ភាគរយនៃថវិការួមរបស់ក្រសួង សម្រាប់ចំណាយលើការអភិវឌ្ឍសមត្ថភាពនិងស្ថាប័ន
- ការទម្លាក់ថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានភាពយឺតយ៉ាវ សម្រាប់មុខងារដែលបានផ្ទេរទៅថ្នាក់ក្រោមជាតិ
- ថ្នាក់ដឹកនាំ និងមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុនៅតាមអង្គភាព និងសាលារៀនសាធារណៈមួយចំនួនមិនទាន់យល់ច្បាស់ពីនីតិវិធីហិរញ្ញវត្ថុ និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ
- សម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា និងប្រព័ន្ធអ៊ីនធឺណេតនៅតាមសាលារៀនសាធារណៈមិនទាន់ឆ្លើយទៅនឹងតម្រូវការប្រើប្រាស់ប្រព័ន្ធ EFMS ដែលមានលក្ខណៈ Online
- មិនទាន់មានមជ្ឈមណ្ឌលទិន្នន័យសម្រាប់រក្សាទុកទិន្នន័យបម្រុង ដូចជា៖ ទិន្នន័យហិរញ្ញវត្ថុ ទិន្នន័យបុគ្គលិក ទិន្នន័យកីឡា ទិន្នន័យរបស់មជ្ឈមណ្ឌលសម្រាប់ការអប់រំឌីជីថល និងការអប់រំពីចម្ងាយ
- មិនទាន់បានធ្វើសន្ធានកម្មរវាងប្រព័ន្ធ EFMS និងប្រព័ន្ធ FMIS របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាហេតុធ្វើឱ្យបង្កើនការងារដល់អ្នកប្រើប្រាស់
- មិនទាន់បានចុះកិច្ចព្រមព្រៀងសមិទ្ធកម្មកម្រិតទី៣ រវាងប្រធានកម្មវិធីជាមួយនឹងអង្គភាពថវិកា

- មិនទាន់កែសម្រួលរចនាសម្ព័ន្ធថវិកាកម្មវិធីរបស់ក្រសួង ឱ្យស្របតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨
- មិនទាន់អាចគ្រោងថវិកាបន្ទុកបុគ្គលិក (ជំពូក៦៤) និងថវិកាវិនិយោគ(ជំពូក២១) តាមអនុកម្មវិធី និងតាមកម្មវិធី
- មិនអាចបូកសរុបថវិការបស់ការិយាល័យ អ.យ.ក នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងមិនបានរំលេចនូវថវិកាអប់រំ យុវជន និងកីឡា ដាច់ដោយឡែកពីអនុវិស័យផ្សេងៗនៃសៀវភៅថវិកានៅថ្នាក់ក្រោមជាតិ។

### ៣.១.៨ ការងារកិច្ចលទ្ធកម្ម

- កញ្ចប់លទ្ធកម្មដែលរងវិចារណកម្មចំណាយ និងកញ្ចប់លទ្ធកម្មដែលអនុវត្តជាពីរជំហាន បានធ្វើឱ្យអូសបន្លាយពេលវេលាអនុវត្តកិច្ចលទ្ធកម្មរហូតដល់ចុងឆ្នាំ
- គម្រោងចំណាយលទ្ធកម្មដែលមានទឹកប្រាក់តិច ពុំសូវមានក្រុមហ៊ុនចូលរួមប្រកួតប្រជែង
- អង្គភាពថវិកាមួយចំនួនមានតម្រូវការចំណាយលទ្ធកម្មនៅពាក់កណ្តាលឆ្នាំ
- ប្រព័ន្ធដំណើរការ FMIS សម្រាប់មុខងារលទ្ធកម្ម មិនទាន់ដំណើរការបានដោយរលូន។

### ៣.១.៩ ការងារបណ្តុះបណ្តាល និងវិក្រឹតការ

- មិនទាន់មានប្រព័ន្ធព័ត៌មានគ្រប់គ្រងសាលាគរុកោសល្យ
- មិនទាន់មានប្រព័ន្ធគ្រប់គ្រងការបំពេញការងារបុគ្គលិកផ្ទៃក្នុងនាយកដ្ឋាន
- គុណវុឌ្ឍិគ្រូឧទ្ទេសមិនទាន់ឆ្លើយតបទៅនឹងការត្រៀមបណ្តុះបណ្តាលគ្រូបង្រៀន ១២+៤ និងបរិញ្ញាបត្រ+១
- គ្រូឧទ្ទេសដែលមានគុណវុឌ្ឍិខ្ពស់តែមិនទាន់បាននិយ័តគ្រប់ខណ្ឌ
- គុណវុឌ្ឍិរបស់មន្ត្រីមិនទាន់ឆ្លើយតបទៅនឹងបរិវត្តកម្មអប់រំ។

### ៣.១.១០ ការងាររដ្ឋបាល

- សកម្មភាពក្នុងផែនការមិនបានអនុវត្តដោយខ្វះធនធាន។

### ៣.១.១១ ការងារសំណង់សិក្សា

- ពុំទាន់មានប្រព័ន្ធគ្រប់គ្រងព័ត៌មានសំណង់ ដើម្បីពិនិត្យតាមដាន និងវាយតម្លៃលើតម្រូវការសាងសង់ និងជួសជុល
- ខ្វះមន្ត្រីជំនាញរដ្ឋបាល ផែនការ វិស្វករសំណង់អគ្គិសនី (ទឹកភ្លើង) ស្ថាបត្យករ និងព័ត៌មានវិទ្យា ដើម្បីជំរុញការងារឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

### ៣.១.១២ ការងារអធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

- ខ្វះមន្ត្រីបំពេញការងារ
- សកម្មភាពក្នុងផែនការមិនបានអនុវត្តដោយខ្វះធនធាន។

### ៣.១.១៣ ការងារសវនកម្មផ្ទៃក្នុង

- សមត្ថភាពសវនករផ្ទៃក្នុង ធ្វើសវនកម្មសមិទ្ធកម្ម ធ្វើសវនកម្មបច្ចេកវិទ្យាព័ត៌មាន និងធ្វើសវនកម្មគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍នៅមានកម្រិត

- ការធ្វើសវនកម្មជាប្រចាំមិនទាន់ឆ្លើយតបទៅនឹងសៀវភៅណែនាំសវនកម្មផ្ទៃក្នុង របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**៣.១.១៤ ការងារអធិការកិច្ចគុណភាពអប់រំ**

- ខ្វះអ្នកបច្ចេកទេស សម្រាប់ពិគ្រោះយោបល់ក្នុងជួយការរៀបចំក្របខណ្ឌអធិការកិច្ចគុណភាពអប់រំ
- ខ្វះកុំព្យូទ័រក្តារបន្ទះ សម្រាប់ធ្វើតេស្តវាយតម្លៃលទ្ធផលសិក្សាសិស្សក្នុងពេលធ្វើអធិការកិច្ចសាលារៀន។

**៣.១.១៥ ការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងសំណង់**

- ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ថ្នាក់មូលដ្ឋាន នៅមានកម្រិត និងមិនទាន់ពេលវេលា
- មិនមានរបាយការណ៍សំណង់ និងសម្ភារបរិក្ខារ ពីសប្បុរសជន និងដៃគូអភិវឌ្ឍន៍នានាផ្ទាល់ពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ។

**៣.២ បញ្ហាប្រឈមអនុវិស័យ**

**៣.២.១ អនុវិស័យ ការអប់រំកុមារតូច**

- ការអនុវត្តអភិបាលកិច្ចសាលាមត្តេយ្យសិក្សានៅមិនទាន់បានពេញលេញ
- ការពង្រីកសេវាអប់រំកុមារតូចនៅមិនទាន់ឆ្លើយតបនឹងតម្រូវការ
- ការអនុវត្តលិខិតបទដ្ឋានគតិយុត្តគាំទ្រការគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅមិនទាន់ឆ្លើយតបបានពេញលេញ
- ពុំទាន់មានលិខិតបទដ្ឋានគតិយុត្តគាំទ្រការបង្កើតទារកដ្ឋាន និងការអភិវឌ្ឍកុមារតូច ១ ០០០ ថ្ងៃដំបូង
- សមត្ថភាពបុគ្គលិកអប់រំផ្នែកអប់រំកុមារតូចនៅមិនទាន់ឆ្លើយតបតាមក្របខណ្ឌគុណវុឌ្ឍិ
- ខ្វះគ្រូបង្រៀនមត្តេយ្យសិក្សានៅតាមសាលាមត្តេយ្យសិក្សា និងមត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា។

**៣.២.២ អនុវិស័យ ការអប់រំបឋមសិក្សា**

- ខ្វះគ្រូបង្រៀនដែលមានគុណវុឌ្ឍិ
- គណៈគ្រប់គ្រងសាលារៀនភាគច្រើន មិនបានទទួលការបណ្តុះបណ្តាលសមត្ថភាព ស្តីពីការដឹកនាំគ្រប់គ្រងសាលារៀន និងមិនមានការចុះកិច្ចព្រមព្រៀងលទ្ធផល
- ការអនុវត្តកញ្ចប់សម្ភារអំណាន និងគណិតវិទ្យាថ្នាក់ដំបូង ព្រមទាំងកម្មវិធីប្រឹក្សាគរុកោសល្យទើបបានប្រមាណ ៥០ភាគរយ នៃកម្រិតថ្នាក់ទី១ ទី២ និងទី៣ ទូទាំងប្រទេស
- ខ្វះអគារសិក្សា ខ្វះហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យការបង្រៀននិងរៀន បណ្ណាល័យ បន្ទប់កុំព្យូទ័រ និងការអប់រំឌីជីថល
- ផ្ទះបាយសាលារៀន និងកន្លែងសិស្សហូបអាហារ មិនទាន់ស្របតាមស្តង់ដា និងឆ្លើយតបទៅនឹងតម្រូវការសិស្ស ក្រោមកម្មវិធីផ្តល់អាហារតាមសាលារៀន។

**៣.២.៣ អនុវិស័យ ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស**

- ការអនុវត្តការបង្រៀននិងរៀនពេញមួយថ្ងៃមិនទាន់បានពេញលេញ

- ខ្វះគ្រូបង្រៀនតាមនិយាមឯកទេសមុខវិជ្ជា
- ខ្វះហេដ្ឋារចនាសម្ព័ន្ធសម្រាប់បម្រើឱ្យការងារបង្រៀន និងរៀន
- ខ្វះធនធានសម្រាប់អនុវត្តប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា
- ការផ្សព្វផ្សាយឯកសារគំរូលំនាំបង្រៀន ការអនុវត្តកម្មវិធីសិក្សាថ្មី វិធីសាស្ត្របង្រៀន និងការកសាងសម្ភារឧបទេសនៅមិនទាន់បានទូលំទូលាយ
- គ្រឹះស្ថានសិក្សាអប់រំបច្ចេកទេសមួយចំនួនមិនអាចអនុវត្តកម្មវិធីសិក្សាឱ្យបានពេញលេញ
- គ្រូបង្រៀនបច្ចេកទេសមួយចំនួនមិនមានសមត្ថភាពប្រើប្រាស់សម្ភារបរិក្ខារគាំទ្រការបង្រៀននិងរៀនប្រកបដោយ ប្រសិទ្ធភាព និងប្រសិទ្ធផល។

**៣.២.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា**

- តម្រូវការសមត្ថភាព និងចំនួនមន្ត្រីជំនាញបន្ថែម ដើម្បីគាំទ្រដល់ការអនុវត្តកំណែទម្រង់កម្មវិធីអប់រំតាមបែបការអប់រំផ្អែកលើលទ្ធផល ការស្រាវជ្រាវ និងអភិបាលកិច្ចនៅតាមគ្រឹះស្ថានឧត្តមសិក្សា
- តម្រូវការបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធ សម្ភារូបវន្ត និងបច្ចេកវិទ្យាឌីជីថល ដើម្បីគាំទ្រដល់ការអនុវត្តកំណែទម្រង់កម្មវិធីអប់រំតាមបែបការអប់រំផ្អែកលើលទ្ធផល ការស្រាវជ្រាវ និងអភិបាលកិច្ចនៅតាមគ្រឹះស្ថានឧត្តមសិក្សា
- អត្រានិស្សិតបោះបង់អាហារូបករណ៍រដ្ឋមានការកើនឡើងខ្ពស់
- តម្រូវការសមត្ថភាព និងមន្ត្រីជំនាញបន្ថែម ដើម្បីគាំទ្រដល់ការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងនៅតាមគ្រឹះស្ថានឧត្តមសិក្សា ឆ្ពោះទៅការទទួលស្គាល់គុណភាពពីខាងក្រៅដោយទីផ្សារការងារ និងស្ថាប័ន/ភ្នាក់ងារទទួលស្គាល់គុណភាពថ្នាក់ជាតិ អន្តរជាតិ
- តម្រូវការមូលនិធិស្រាវជ្រាវនៅឧត្តមសិក្សា ដើម្បីធានានិរន្តរភាពនៃការស្រាវជ្រាវ និងការអភិវឌ្ឍ
- គ្រឹះស្ថានឧត្តមសិក្សានៅមិនទាន់បានរៀបចំផែនការយុទ្ធសាស្ត្ររយៈពេលវែង និងមធ្យម ស្របតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១។

**៣.២.៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ និងអប់រំបរិយាបន្ន**

- ការអនុវត្តកម្មវិធីអក្ខរកម្មសម្រាប់កម្មករ កម្មការិនីតាមរោងចក្រ កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ និងកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត មិនទាន់បានទូលំទូលាយ
- ការបណ្តុះបណ្តាលគ្រូជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធមិនបានពេញលេញ
- ការអនុវត្តក្របខណ្ឌវាយតម្លៃស្ថានភាពដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍ពុំទាន់បានគ្រប់រាជធានី ខេត្ត
- មន្ត្រីអប់រំក្រៅប្រព័ន្ធថ្នាក់ក្រោមជាតិក្នុងការប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ (NFE-MIS) ពុំទាន់បានបណ្តុះបណ្តាល
- ការយល់ដឹងអំពីពិការភាព ការអប់រំបរិយាបន្នរបស់គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀននៅមានកម្រិត

- សមត្ថភាពគ្រូបង្រៀនក្នុងការជួយសិស្សដែលមានតម្រូវការពិសេសតាមសាលារៀននៅមានកម្រិត
- សមត្ថភាពគ្រូបង្រៀននៅវិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្មលើវិធីសាស្ត្របង្រៀនតាមមុខវិជ្ជា និងជំនាញអប់រំពិសេសនៅមានកម្រិត
- ខ្វះគ្រូបង្រៀនជំនាញអប់រំពិសេស សម្រាប់បង្រៀនថ្នាក់សមាហរណកម្មផ្នែកសតិបញ្ញា និងអូទីស្ស៊ីម
- កម្មវិធីសិក្សា និងសៀវភៅសិក្សាសម្រាប់កម្មវិធីអប់រំពហុភាសា នៅអនុវត្តកម្មវិធីចាស់។

### ៣.២.៦ អនុវិស័យ ការអភិវឌ្ឍយុវជន

- កម្មវិធីយុវជននៅមិនទាន់ឆ្លើយតបនឹងតម្រូវការរបស់យុវជននៅតាមរាជធានី ខេត្ត
- ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ សម្ភាររូបវន្ត ការផ្តល់សេវាកម្ម និងការអនុវត្តកម្មវិធីយុវជននៅតាមមជ្ឈមណ្ឌលយុវជន មិនទាន់ឆ្លើយតបទៅនឹងការបណ្តុះបំណិនសតវត្សរ៍ទី២១
- ធនធានមនុស្សដែលមានវិជ្ជាជីវៈការអភិវឌ្ឍយុវជន នៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការកម្មវិធីយុវជន។

### ៣.២.៧ អនុវិស័យ ការអភិវឌ្ឍអប់រំកាយនិងកីឡា

- ការអនុវត្តកម្មវិធីសិក្សា និងកាលវិភាគម៉ោងអប់រំកាយ និងកីឡា ២ម៉ោងក្នុង១សប្តាហ៍មិនទាន់បានពេញលេញ ដោយសារការខ្វះខាតគ្រូកីឡា និងម៉ោងសិក្សា
- គុណវុឌ្ឍិគ្រូឧទ្ទេសនៅវិទ្យាស្ថានជាតិអប់រំកាយនិងកីឡានៅមិនទាន់ឆ្លើយតបតាមតម្រូវការសម្រាប់បណ្តុះបណ្តាលកម្រិតឧត្តមសិក្សា
- ខ្វះសម្ភារបច្ចេកវិទ្យាសម្រាប់បម្រើការក្នុងការបង្រៀននិងរៀននៅវិទ្យាស្ថានជាតិអប់រំកាយនិងកីឡា
- ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារបច្ចេកទេសកីឡាមិនទាន់ឆ្លើយតបតាមតម្រូវការ និងតាមនិយាមបច្ចេកទេសអន្តរជាតិ
- ខ្វះមន្ត្រីវេជ្ជសាស្ត្រកីឡាសម្រាប់ការងារព្យាបាល គ្រប់គ្រង និងធ្វើតេស្តវាយតម្លៃគុណផលកីឡារបស់អត្តពលិក
- ខ្វះមន្ត្រីជំនាញវិទ្យាសាស្ត្រកីឡា រួមទាំងមន្ត្រីជំនាញផ្នែកអាហារូបត្ថម្ភ ដើម្បីគាំទ្រដល់ការហាត់ហ្វឹកហ្វឺន ក្នុងគោលដៅលើកកម្ពស់គុណផលកីឡា និងអភិវឌ្ឍកីឡាកម្រិតខ្ពស់។

## ៤. ទិសដៅឆ្នាំ២០២៥

### ៤.១ ទិសដៅរួម

### ៤.១.១ ការងារគោលនយោបាយ ផែនការ ស្ថិតិ និងការពិនិត្យតាមដាននិងវាយតម្លៃ

- ពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកផែនការនៅគ្រប់កម្រិត
- បន្សុីរចនាសម្ព័ន្ធថវិកាកម្មវិធី និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨
- ពង្រឹងយន្តការ និងប្រព័ន្ធសម្របសម្រួល និងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ
- សិក្សាស្រាវជ្រាវអំពីវិធីសាស្ត្រវិភាគបញ្ហាកម្រិតសាលារៀន
- ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគេហទំព័រប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ
- ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យអប់រំអនឡាញ

- ពង្រីកការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យសិស្សអនឡាញ (STS) នៅទូទាំងក្រុង ស្រុក ក្នុងខេត្តសៀមរាប
- ពង្រីកការបណ្តុះបណ្តាល និងប្រើប្រាស់គ្រប់គ្រងទិន្នន័យសិស្សអនឡាញ (STS) នៅបណ្តា ១០ រាជធានី ខេត្ត គោលដៅ
- បន្តពង្រឹងយន្តការការងារប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំសាលារៀនចំណេះទូទៅសាធារណៈ ឯកជន និងមេត្តយ្យសិក្សាសហគមន៍ តាមរយៈឧបករណ៍ប្រមូលទិន្នន័យអប់រំ
- រៀបចំផ្តួចផ្តើមលើការងាររៀបចំផែនទីបណ្តាញសាលារៀនផ្សារភ្ជាប់ទៅនឹងបណ្តាញអ៊ីនធឺណិត
- បន្តចុះគាំទ្រ និងពង្រឹងសមត្ថភាពដើម្បីធ្វើបច្ចុប្បន្នភាពលើការ "ប្រមូលទិន្នន័យក្នុងការធ្វើផែនទីសាលារៀន" នៅតាមបណ្តាក្រុង ស្រុក ខណ្ឌ ទូទាំង២៥ រាជធានី ខេត្ត
- អភិវឌ្ឍសមត្ថភាពមន្រ្តីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិលើការងារប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ
- បន្តអភិវឌ្ឍ "ប្រព័ន្ធគ្រប់គ្រងទិន្នន័យអប់រំ OpenEMIS" លើការរចនាប្រព័ន្ធ និងការងាររៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យអប់រំ
- បញ្ចប់ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្មវិស័យអប់រំ យុវជន និងកីឡា
- ការអភិវឌ្ឍសមត្ថភាពស្តីពីការរៀបចំក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្មវិស័យអប់រំ យុវជន និងកីឡាថ្នាក់រាជធានី ខេត្ត ដល់មន្រ្តីអប់រំថ្នាក់រាជធានី ខេត្ត
- ពិនិត្យតាមដាន និងវាយតម្លៃគម្រោងអភិវឌ្ឍ វិស័យអប់រំ យុវជន និងកីឡា
- រៀបចំរបាយការណ៍ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តគម្រោងអភិវឌ្ឍ វិស័យអប់រំ យុវជន និងកីឡា
- គាំទ្របច្ចេកទេសលើការរៀបចំរបាយការណ៍សន្និបាតអប់រំ យុវជន និងកីឡា
- ពិនិត្យតាមដានការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ដើម្បីជំរុញការអនុវត្ត។

### ៤.១.២ ការងារវិមជ្ឈការ និងវិសហមជ្ឈការ

- កសាងលិខិតបទដ្ឋានគតិយុត្តគាំទ្រការងារកំណែទម្រង់ច្បាប់ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំ
- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តវិស័យអប់រំ
- ពង្រឹងយន្តការពិនិត្យតាមដានការផ្តល់សេវាសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា និងការវាយតម្លៃទទួលស្គាល់គ្រឹះស្ថានសិក្សាឯកជន
- កែសម្រួលឯកសារស្តីពីអភិបាលកិច្ចល្អសម្រាប់ពង្រឹងការផ្តល់សេវាអប់រំ ដើម្បីរួមចំណែកសម្រេចបានការអនុវត្តស្តង់ដាសាលារៀនគំរូ
- ពិនិត្យតាមដាន និងគាំទ្ររដ្ឋបាលក្រុង ស្រុក លើការអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានផ្ទេរជូនរដ្ឋបាលក្រុង ស្រុក
- អភិវឌ្ឍសមត្ថភាពគ្រប់គ្រង និងដោះស្រាយវិវាទបុគ្គលិកអប់រំ។

### ៤.១.៣ ការងារគ្រប់គ្រងបុគ្គលិក

- បច្ចុប្បន្នភាពទិន្នន័យព័ត៌មានមន្រ្តីរាជការស៊ីវិល
- កំណែទម្រង់ប្រព័ន្ធវាយតម្លៃដោយផ្អែកលើសមិទ្ធកម្ម

- អភិវឌ្ឍសមត្ថភាពមន្ត្រី និងផែនការពង្រាយមន្ត្រី
- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងវត្តមាន
- ទំនើបកម្មប្រព័ន្ធគ្រប់គ្រងការងារ HRD
- ចូលរួមរៀបចំផែនការពង្រឹងការជ្រើសរើសគ្រូបង្រៀនឱ្យមានគុណភាពល្អ។

**៤.១.៤ ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS) លើមុខងារគ្រប់គ្រងថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ ដោយបន្ថែមបណ្ណព័ត៌មានសាលារៀន (School Profile)
- សម្រួចសកម្មភាពអាទិភាពឆ្លើយតបនឹងកំណែទម្រង់វិស័យអប់រំ និងបរិបទអប់រំឌីជីថល ដើម្បីកៀរគរ និងបង្កើនថវិកាប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡាឱ្យឆ្លើយតបទៅនឹងសូចនាករគោលដៅ ២០ភាគរយ នៃចំណាយចរន្តថ្នាក់ជាតិ
- ចូលរួមអនុវត្តផែនការសកម្មភាពលម្អិត សម្រាប់ការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៤ ឆ្នាំ ២០២៥ (GDAP/MAP-២០២៥) ដើម្បីចូលរួមគាំទ្រកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ,
- កែសម្រួលច្បាប់គតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ នៅតាមអង្គភាពនិងសាលារៀនសាធារណៈ
- ចងក្រងសៀវភៅគោលការណ៍ណែនាំ ស្តីពីនីតិវិធីការអនុវត្តថវិកាថ្នាក់រាជធានី ខេត្ត និង បន្តរៀបចំសៀវភៅ ស្តីពីនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុស្តង់ដាសម្រាប់ថវិកាហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍របស់ក្រសួង
- បន្តអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS) បញ្ចប់លើមុខងារគ្រប់គ្រងថវិកាដៃគូអភិវឌ្ឍន៍ និងចំណូលមិនមែនសារពើពន្ធសម្រាប់ថ្នាក់ជាតិ គ្រប់គ្រងថវិកាផ្ទេរទៅថ្នាក់ក្រោមជាតិ (ការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ)
- ធ្វើសន្ទានកម្មរវាងប្រព័ន្ធ EFMS របស់ក្រសួងអប់រំ យុវជន និងកីឡា ជាមួយប្រព័ន្ធ FMIS របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើសន្ទានកម្ម ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS) ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងធនធានមនុស្ស (HRMIS) និងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS)
- កែសម្រួលអង្គភាពថវិកា ឱ្យស្ថិតនៅកម្រិតអគ្គនាយកដ្ឋាន ព្រមទាំងប្រែក្លាយអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ឱ្យទៅជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញជាបន្តបន្ទាប់តាមផែនការដែលបានគ្រោងទុក
- រៀបចំវេទិកាសាធារណៈ ស្តីពីថវិកាក្រសួងអប់រំ យុវជន និងកីឡា និងសៀវភៅថវិកាពលរដ្ឋ។

**៤.១.៥ ការងារកិច្ចលទ្ធកម្ម**

- ជំរុញការរៀបចំ និងការអនុវត្តផែនការតម្រូវការចំណាយលទ្ធកម្មប្រចាំឆ្នាំឱ្យបានទាន់ពេលវេលា
- ពង្រឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការបញ្ចូលទិន្នន័យសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំផែនការអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញ។

### ៤.១.៦ ការងារបណ្តុះបណ្តាល និងកិច្ចការវិក្រឹតការការងារបណ្តុះបណ្តាល

- ធ្វើបច្ចុប្បន្នកម្មគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣ និងស្តង់ដាសមត្ថភាពនាយកសាលាគរុកោសល្យឆ្នាំ២០១០
- រៀបចំយន្តការ និងឯកសារពាក់ព័ន្ធស្តីពីអាជ្ញាបណ្ណវិជ្ជាជីវៈគ្រូបង្រៀន
- គាំទ្រសាលាគរុកោសល្យឱ្យក្លាយទៅជាសាលាគរុកោសល្យគំរូចំនួន៥
- ជំរុញឡើងគុណវុឌ្ឍិគណៈគ្រប់គ្រង និងគ្រូឧទ្ទេសទៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតទាំងក្នុងស្រុក និងក្រៅស្រុក
- រៀបចំវគ្គបណ្តុះបណ្តាលតាមបែបចម្រុះ ដើម្បីអភិវឌ្ឍសមត្ថភាពគណៈគ្រប់គ្រង និងគ្រូឧទ្ទេសផ្អែកលើតម្រូវការជាក់ស្តែង
- គាំទ្រមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពង់ចាម ព្រៃវែង តាកែវ កណ្តាល ដើម្បីប្រែក្លាយជាវិទ្យាស្ថានគរុកោសល្យ
- រៀបចំកម្រងព័ត៌មានសាលាគរុកោសល្យ បុគ្គលិកអប់រំ និងគរុសិស្ស គរុនិស្សិតនៅតាមសាលាគរុកោសល្យ
- គាំទ្រសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ក្លាយជាគ្រឹះស្ថានផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គ្រូបង្រៀន
- គាំទ្រសាលាគរុកោសល្យដែលមានសក្តានុពលអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សា និងអនុវិទ្យាល័យតាមប្រព័ន្ធ១២+៤
- គាំទ្រសាលាគរុកោសល្យដែលមានសក្តានុពលអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនមត្តេយ្យសិក្សាតាមប្រព័ន្ធ១២+២ បង់ថ្លៃ
- បញ្ចូលខ្លឹមសារមុខវិជ្ជាវាយតម្លៃការសិក្សាក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ និងពង្រឹងសមត្ថភាពគ្រូឧទ្ទេស។

➢ **ការងារកិច្ចការវិក្រឹតការ**

- ពង្រីកវិសាលភាពការអនុវត្តប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅកម្រិតសាលារៀន
- អភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងកម្មវិធីទូរស័ព្ទដៃវៃឆ្លាត (CPD Mobile Application) ដោយភ្ជាប់ថ្នាលអភិវឌ្ឍសមត្ថភាពនានា
- ជំរុញ និងពង្រឹងការអនុវត្តកម្មវិធីដំឡើងគុណវុឌ្ឍិបុគ្គលិកអប់រំតាមគ្រប់រូបភាព
- សិក្សាពីការរៀបចំកម្មវិធីឌីជីថលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- អភិវឌ្ឍផែនការគោល ស្តីពីការដំឡើងគុណវុឌ្ឍិបុគ្គលិកអប់រំ ២០២៦-២០៣០
- រៀបចំកម្មវិធីវិក្រឹតការដោយផ្អែកលើឧត្តមានុវត្តពីសាលារៀនជំនាន់ថ្មី សាលាជាប់ស្តង់ដាសាលារៀនគំរូ និងសាលាដែលនៅក្នុងគម្រោងផ្សេងៗ
- គាំទ្រសាលាគរុកោសល្យដែលមានសក្តានុពលឱ្យក្លាយជាអ្នកផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- ពង្រឹងការអនុវត្តប្រព័ន្ធប្រឹក្សាគរុកោសល្យ និងសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតសាលារៀន
- ជួយគាំទ្រសាលារៀនឱ្យសម្រេចបានស្តង់ដាសាលារៀនគំរូជាពិសេសស្តង់ដាទី២ ការបង្រៀន និងរៀន
- អភិវឌ្ឍសមត្ថភាពផ្ទៃក្នុងនាយកដ្ឋានកិច្ចការវិក្រឹតការ។

### ៤.១.៧ ការងាររដ្ឋបាល

- បន្តពង្រឹងការគ្រប់គ្រងលិខិតរដ្ឋបាល ពិសេសចរាចរណ៍លិខិត
- ជំរុញការផ្តល់គ្រឿងឥស្សរិយយសការងារជូនបុគ្គលិកអប់រំនៅថ្នាក់ជាតិ និងក្រោមជាតិ
- អភិវឌ្ឍសមត្ថភាពការងារគ្រប់គ្រងរដ្ឋបាលអប់រំ ពិធីការ របាយការណ៍ និងបណ្ណសារ
- គ្រប់គ្រង និងប្រតិបត្តិការប្រព័ន្ធទិន្នន័យឯកសារ និងបណ្ណសារដ្ឋាន តាមប្រព័ន្ធ admindms.net
- ចុះពិនិត្យតាមដានការងារគ្រប់គ្រងរដ្ឋបាលអប់រំ បណ្ណសារ និងការងារប្រឡងប្រណាំង
- រៀបចំផែនការអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញ។

### ៤.១.៨ ការងារសំណង់សិក្សា

*គម្រោងថវិការដ្ឋ*

- ជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធ នៅរដ្ឋបាលកណ្តាល និង ជួសជុលអគារសិក្សាទ្រុឌទ្រោមនៅតាមបណ្តារាជធានី ខេត្ត (អគារសិក្សា ១៣ ខ្នង ស្មើនឹង ៧២ បន្ទប់ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ) ប្រើថវិកាជំពូក៦១ ឆ្នាំ២០២៥
- ជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសាងសង់អគារសិក្សាថ្មី ចំនួន៧ខ្នង ៨៧បន្ទប់ និងបង្គន់អនាម័យ ៥ខ្នង ២៩បន្ទប់ ប្រើថវិកាជំពូក២១ ឆ្នាំ២០២៥។

*គម្រោងកែលម្អការអប់រំចំណេះទូទៅ GEIP*

- រៀបចំបន្ទប់ពិសោធន៍មុខវិជ្ជា ចំនួន ៣១ខ្នង
- សាងសង់អគារសិក្សាថ្មី ចំនួន ៥២ខ្នង ២៦០បន្ទប់។

*គម្រោងមធ្យមសិក្សា សម្រាប់ការប្រកួតប្រជែងមូលធនមនុស្ស SE4CH*

- ជួសជុលអគារសិក្សា ចំនួន ១២២ ប្រែក្លាយជាបន្ទប់ពិសោធន៍ ២ និងបណ្ណាល័យ ១
- ជួសជុលបន្ទប់ពហុបំណង ២៥ កន្លែងលាងដៃ ៦៨ទីតាំង
- សាងសង់អគារថ្មី ២៣ទីតាំង។

### ៤.១.៩ ការងារបោះពុម្ព និងចែកផ្សាយ

- កែលម្អសៀវភៅសិក្សាគោលមុខវិជ្ជា ភាសាខ្មែរ វិទ្យាសាស្ត្រ សិក្សាសង្គម ប្រវត្តិវិទ្យា ពលរដ្ឋវិទ្យា និងសេដ្ឋកិច្ចវិទ្យា ព្រមទាំងអភិវឌ្ឍ សៀវភៅផ្សេងៗ
- បោះពុម្ពសៀវភៅសិក្សាគោល ហ្វឹកហាត់ និងអំណានបន្ថែម សម្រាប់ផ្គត់ផ្គង់ជូនរដ្ឋ និងលក់ជូនអតិថិជនទូទៅ
- បន្តសហការជាមួយអង្គការ Wolrd Education ដើម្បីអភិវឌ្ឍនិងប្រើប្រាស់ "ប្រព័ន្ធគ្រប់គ្រងការផ្គត់ផ្គង់សៀវភៅសិក្សាគោលជូនសាលារៀន (TnT)"
- ជំរុញនាយក នាយិកាសាលារៀនធ្វើតម្រូវការ និងបញ្ជាក់ការទទួលសៀវភៅសិក្សាគោល តាមប្រព័ន្ធ TnT។

### ៤.១.១០ ការងារអធិការកិច្ច និងបណ្តឹងតវ៉ា

- អធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ការប្រើប្រាស់ និងចាត់ចែងធនធាន ដោយផ្អែកលើអភិក្រមហានិភ័យ និងករណីសង្ស័យនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាចំនួន ៣៧៨អង្គភាព

- ពិនិត្យវឌ្ឍនភាពនៃការកែលម្អតាមអនុសាសន៍អធិការកិច្ចផ្ទៃក្រៅនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ១០ អង្គភាព
- អធិការកិច្ចបណ្តឹងតវ៉ា បណ្តឹងបរិហារចំនួន១២ ករណី
- ពង្រឹងសមត្ថភាពជំនាញមន្ត្រីអធិការកិច្ច
- ចុះធ្វើសម្រង់ព័ត៌មានគ្រឹះស្ថានឯកជន៩ រាជធានី ខេត្ត
- ផ្សព្វផ្សាយរបាយការណ៍អធិការកិច្ចកម្រិតភូមិភាគព្រៃវែង។

### ៤.១.១១ ការងារសវនកម្មផ្ទៃក្នុង

- បច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង ៣ឆ្នាំរំកិល (២០២៥-២០២៧) ស្របតាមរចនាសម្ព័ន្ធក្រសួង
- រៀបចំផែនការសវនកម្មប្រចាំឆ្នាំ២០២៥
- ចុះធ្វើសវនកម្ម និងពិនិត្យតាមដានអនុសាសន៍
- បន្តពង្រឹងការអនុវត្តនីតិវិធីសវនកម្មផ្ទៃក្នុងស្របតាមមុខងារសវនកម្មផ្ទៃក្នុង
- រៀបចំផែនការអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញ
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលសវនកម្មផ្ទៃក្នុង និងសេចក្តីសន្និដ្ឋានជាទៀងទាត់។

### ៤.១.១២ ការងារអធិការកិច្ចគុណភាពអប់រំ

**ការងារអធិការកិច្ច**

- រៀបចំ «ក្របខណ្ឌអធិការកិច្ចធានាគុណភាពអប់រំ»
- ពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេសអធិការកិច្ច និងផ្សព្វផ្សាយលទ្ធផលអធិការកិច្ច ជូនថ្នាក់ក្រោមជាតិតាមរយៈក្រុមបង្គោលតាមតំបន់(៥តំបន់)
- ធ្វើអធិការកិច្ច ធ្វើតេស្តសិស្ស និងវិធីសាស្ត្របង្រៀនការសិក្សាបែបគម្រោង (ការអប់រំស្នែម) នៅតាមសាលារៀនគោលដៅ (ប្រើឧបករណ៍វាយតម្លៃស្តង់ដាសាលារៀនគំរូ)
- ពិនិត្យវឌ្ឍនភាពនៃការអនុវត្តស្តង់ដាសាលារៀនគំរូនៅតាមសាលារៀនដែលបានចុះអធិការកិច្ច។

**ការងារតេស្តវាយតម្លៃលទ្ធផលសិក្សា**

- ជំរុញលើការបន្សាំ ដោយប្រើសំណួរតេស្ត PISA នៅតាម ២០០ សាលារៀនគោលដៅ
- ចុះគាំទ្រការអនុវត្តសំណួរតេស្ត PISA នៅតាម ១៥០ សាលារៀនសំណាក
- រៀបចំសេចក្តីណែនាំស្តីពី «យន្តការបច្ចេកទេសនៃការតាក់តែងសំណួរតេស្ត PISA សម្រាប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈ»
- សហការជាមួយមហាវិទ្យាល័យអប់រំ (សាកលវិទ្យាល័យភូមិន្ទភ្នំពេញ) ដើម្បីរៀបចំ និងធ្វើបច្ចុប្បន្នកម្មសំណួរតេស្តគំរូកម្មវិធី PISA នៅក្នុង GEIP Ed-Tech App
- អនុវត្តគម្រោង Platform for Innovative Learning Assessments (PILA)
- ពង្រឹងសមត្ថភាពក្រុមការងារបច្ចេកទេសថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិពីរបៀបចុះគាំទ្រការអនុវត្តកម្មវិធី SEA-PLM និងPISA នៅកម្រិតសាលារៀន

- សហការជាមួយនាយកដ្ឋានបឋមសិក្សារៀបចំ និងធ្វើបច្ចុប្បន្នកម្មគំរូសំណួរតេស្ត SEA-PLM នៅក្នុង PLP App
- រៀបចំក្របខណ្ឌវាយតម្លៃថ្នាក់ដំបូង សម្រាប់ការអនុវត្តជាតេស្តថ្នាក់ជាតិ
- អនុវត្តសកម្មភាព EGRA / EGMA ដែលគាំទ្រដៃគូអភិវឌ្ឍន៍នានា
- អនុវត្តតេស្តសាកល្បង AMPLa ។

**ការងារវាស់ស្ទង់សមត្ថភាពកម្រិតសមមូល**

- រៀបចំសេចក្តីណែនាំស្តីពីការស្នើសុំ និងផ្តល់វិញ្ញាបនបត្របញ្ជាក់យន្តការវាស់ស្ទង់សមត្ថភាពកម្រិតសមមូលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- រៀបចំឯកសារទស្សនាទានស្តីពី នីតិវិធីការវាស់ស្ទង់សមត្ថភាពកម្រិតសមមូលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ជាមួយអន្តរក្រសួង
- ផ្សព្វផ្សាយប្រកាស ស្តីពីបែបបទ នីតិវិធីនៃការធ្វើការវាស់ស្ទង់កម្រិតសមមូលជូនដល់រាជធានីខេត្តទាំង២៥
- រៀបចំសេចក្តីណែនាំស្តីពី បែបបទ នៃការវាស់ស្ទង់កម្រិតសមមូល ជូនដល់សាមីខ្លួនដែលមានតម្រូវការស្នើសុំវិញ្ញាបនបត្របញ្ជាក់សមមូលទាំងបឋមភូមិ និងទុតិយភូមិ ។

## ៤. ទិសដៅគោលនយោបាយសម្រាប់រួមចំណែកអនុវត្តអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល

ជារួម ដើម្បីចូលរួមចំណែកអនុវត្តអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ២០២៦-២០២៨ ឱ្យមានគុណភាព ត្រូវធានាការផ្សារភ្ជាប់ថវិកាទៅនឹងអាទិភាពគោលនយោបាយដែលមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលថ្មី នីតិកាលទី៧នៃរដ្ឋសភាស្របតាមគោលការណ៍ណែនាំស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងក្នុងក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ត្រូវបន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម ខ្ពស់ ព្រមទាំងសុខុមាលភាពដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ឱ្យបានគ្រប់គ្រាន់តាមតម្រូវការទីផ្សារ។

ក្រោយពេលស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ២០២៦នេះ ដោយមានការគិតគូរក្នុងគោលដៅបង្កើនគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ស្របតាមទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។ ជាពិសេស ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាត្រូវឆ្លុះបញ្ចាំងឱ្យឃើញច្បាស់អំពីគោលបំណងគោលនយោបាយរបស់ក្រសួង កម្មវិធី សូចនាករសមិទ្ធកម្ម សម្រាប់វាស់វែងលទ្ធផលនៃការអនុវត្តកម្មវិធីសមស្របទំហំថវិកា និងលទ្ធភាពថវិកាដែលមាន ជាពិសេសក្នុងការរៀបចំផែនការនេះក៏ត្រូវផ្តោតលើសកម្មភាពអាទិភាពផងដែរ ដើម្បីគាំទ្រដល់ដំណើរការការងារបង្រៀន និងរៀនពីចម្ងាយ តាមអនឡាញ និងប្រព័ន្ធវីដេអូ នូវវិធីសាស្ត្របង្រៀនថ្មីៗ ក្នុងបរិបទការគ្រប់គ្រងតាមសាលារៀនសំដៅឈានទៅសម្រេចគោលនយោបាយអប់រំរបស់ក្រសួង។

លើសពីនេះទៀត ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០២៤-២០២៨ ដើម្បីចូលរួមចំណែកសម្រេចផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០២៤-២០២៨ ក្នុងនោះ ការអភិវឌ្ឍមូលធនមនុស្ស តាមរយៈការលើកកម្ពស់ការអប់រំក្នុងនីតិកាលទី៧ បានបន្តដោយផ្តោតលើ ១)ការពង្រឹងគុណភាព វិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២)ការបណ្តុះបណ្តាលជំនាញបច្ចេកទេស តាមរយៈទស្សនាទាន “ យុវជន មានជំនាញមួយយ៉ាងតិចប្រចាំជីវិត” ។

ក្នុងដំណាក់កាលនេះ ក្រសួងអប់រំ យុវជន និងកីឡាបានបន្តផ្តោតលើអាទិភាពកំណែទម្រង់វិស័យអប់រំ ក្នុងនោះរួមមាន៖ (១)កំណែទម្រង់គោលនយោបាយកម្រិតថ្នាក់ជាតិ (២)កំណែទម្រង់ការអប់រំគ្រូបង្រៀន នៅតាមសាលាគរុកោសល្យ និងវិក្រឹតការ និង(៣)កំណែទម្រង់កម្រិតសាលារៀន។

ជាងនេះទៅទៀត ក្រសួងកំពុងបន្តអនុវត្តកំណែទម្រង់គោលនយោបាយកម្រិតថ្នាក់ជាតិ ដែលក្នុងនោះ រួមមាន៖ (១)ការអនុវត្តកំណែទម្រង់តាមសសរស្តម្ភទាំង៥ (២)ការអនុវត្តកម្មវិធីសិក្សាថ្មីនិងសៀវភៅសិក្សាគោល ដោយផ្តោតលើវិធីសាស្ត្របង្រៀនថ្មី (៣)កំណែទម្រង់ការគ្រប់គ្រងអប់រំ និង(៤)កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ (៥)កំណែទម្រង់ការអប់រំគ្រូបង្រៀននៅតាមសាលាគរុកោសល្យ (៦)កំណែទម្រង់កម្រិតសាលារៀន (៧)កំណែទម្រង់កម្រិតឧត្តមសិក្សា (៨)កំណែទម្រង់ការអភិវឌ្ឍ យុវជន និង(៩)កំណែទម្រង់ការអប់រំកាយ និងកីឡា ជាពិសេស ក្រសួងអប់រំ យុវជន និងកីឡាទើបតែបានកែសម្រួលបង្រួមគោលនយោបាយអប់រំឱ្យនៅតែមួយក្នុងគោលបំណងសំដៅលើ “**ធានាឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត**” ដើម្បីធានាឱ្យការរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះមានលក្ខណៈអនុវិស័យ ក្នុងការរួមចំណែកសម្រេចគោលនយោបាយរាជរដ្ឋាភិបាលផងដែរ។

គោលនយោបាយយុទ្ធសាស្ត្រ កម្មវិធី និងចង្កោមសកម្មភាព ជាអាទិភាពរបស់ក្រសួងត្រូវបានសម្រេចដើម្បីឆ្លើយតបទៅនឹងប្រព័ន្ធអប់រំមួយ ដែលធានាគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធពីសំណាក់ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធ ក្នុងការប្រើប្រាស់ឱ្យអស់សក្តានុពលធនធានសរុប ដើម្បីឈានទៅអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។

## II. គោលបំណងគោលនយោបាយ

ក្រសួងអប់រំ យុវជន និងកីឡាបានកែសម្រួលខ្លឹមសារដែលមានលក្ខណៈគ្របដណ្តប់ជាកម្មវិធីលើគោលនយោបាយអប់រំ ដើម្បីធានាឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត ដើម្បីរួមចំណែកអនុវត្តគោលនយោបាយតាមអនុវិស័យ ជាពិសេសគោលនយោបាយ រួមរបស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចឱ្យបាននូវគោលដៅដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ក្រសួងអប់រំ យុវជន និងកីឡា មានគោលបំណងគោលនយោបាយ ដូចខាងក្រោម៖

| គោលបំណងគោលនយោបាយ | បម្រើឱ្យគោលដៅយុទ្ធសាស្ត្រ និង វិធានការគោលនយោបាយនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ | ស្ថិតនៅក្នុងវិស័យណាមួយនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
|---|---|---|
| ធានាឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត។ | ការអភិវឌ្ឍមូលធនមនុស្ស មុំទី១៖ ការពង្រឹងគុណភាពវិស័យអប់រំ យុវជន និងកីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដោយផ្តោតលើ៖ ១) ការបន្តពង្រឹងគុណភាពអប់រំ និងការបណ្តុះបណ្តាលគ្រប់កម្រិត ការធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សាគ្រប់កម្រិត និងការបង្កើតបរិយាកាសល្អសម្រាប់ការសិក្សាពេញមួយជីវិត ២) បង្កើតសាលារៀនជំនាន់ថ្មីនិងសាលាគំរូ ការពង្រឹងអភិបាលកិច្ច និងប្រសិទ្ធភាពគ្រប់គ្រងនៅមន្ទីរអប់រំ យុវជន និងកីឡា ព្រមទាំងការជំរុញការចូលរួម និងភាពជាម្ចាស់របស់មាតាបិតា សហគមន៍ និងវិស័យឯកជន ៣) ការពង្រឹងគុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន និងវិធីសាស្ត្របង្រៀន ព្រមទាំងការបន្តលើកកម្ពស់ជីវភាព និងគុណតម្លៃបុគ្គលិកសិក្សាគ្រប់កម្រិត ៤) ការបន្តលើកកម្ពស់ការអប់រំឌីជីថល ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលតាមសាលារៀន និងការជំរុញនូវការចាប់យកមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា ៥) ការលើកកម្ពស់សុខភាពសិក្សា និងការបង្កើនអាហារូបករណ៍សម្រាប់សិស្ស និស្សិតក្រីក្រ និងរងគ្រោះ ៦) ការពង្រឹងអភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា ការលើកកម្ពស់ការស្រាវជ្រាវ ការអភិវឌ្ឍ | ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស |

| | | |
|---|---|---|
| | និងការនេវានុវត្តន៍ និងការជំរុញភាពជាដៃគូរវាងរដ្ឋ និងឯកជន និង៧) ការលើកកម្ពស់វិស័យកីឡាផ្សារភ្ជាប់នឹងការអប់រំ និងការបន្តជំរុញចលនា "យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត"។ | |

## III. ការរៀបចំកម្មវិធី

ដើម្បីអនុវត្តគោលបំណងគោលនយោបាយខាងលើឱ្យទទួលបានជោគជ័យ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំកម្មវិធីចំនួន៥ ដូចខាងក្រោម៖

**១. កម្មវិធីទី១៖ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ**

**គោលបំណងនៃកម្មវិធី៖** ពង្រីកសេវាអប់រំកុមារតូចតាមគ្រប់រូបភាពសម្រាប់កុមារអាយុពី ០ឆ្នាំ ទៅក្រោម៦ឆ្នាំ បង្កើនអត្រាបញ្ចប់ការសិក្សាសម្រាប់ការអប់រំចំណេះទូទៅ និងបង្កើនអត្រាអក្ខរកម្មជនពេញវ័យ។

**២. កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ**

**គោលបំណងនៃកម្មវិធី៖** អភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវឱ្យឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងឧស្សាហកម្ម។

**៣. កម្មវិធីទី៣៖ ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា**

**គោលបំណងនៃកម្មវិធី៖** លើកកម្ពស់ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា សំដៅលើសុខុមាលភាពប្រជាពលរដ្ឋ និងការប្រកួតកីឡាគ្រប់ប្រភេទឱ្យមានគុណផលកីឡា។

**៤. កម្មវិធីទី៤៖ ការអភិវឌ្ឍយុវជន**

**គោលបំណងនៃកម្មវិធី៖** អនុវត្តគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា និងឆ្លើយតបតាមតម្រូវការចាំបាច់របស់យុវជន។

**៥. កម្មវិធីទី៥៖ ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ**

**គោលបំណងនៃកម្មវិធី៖** ពង្រឹងអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផលការងារវិមជ្ឈការ និងវិសហមជ្ឈការ និងការបង្កើតភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។

ដើម្បីគាំទ្រកម្មវិធីទាំង៥ ខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំអនុកម្មវិធីចំនួន ៥៥ ក្នុងនោះ អនុកម្មវិធីចំនួន ៤ ត្រូវអនុវត្តរួមគ្នាដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។ អនុកម្មវិធីទាំង៥៥ មានដូចតទៅ៖

កម្មវិធីទី១៖ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ

១. អនុកម្មវិធីទី១.១៖ ការពង្រីកការអប់រំកុមារតូច

គោលបំណងនៃអនុកម្មវិធី៖ បង្កើនលទ្ធភាពទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន។

២. អនុកម្មវិធីទី១.២៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា

គោលបំណងនៃអនុកម្មវិធី៖ ប្រមូលកុមារដល់ និងក្នុងវ័យសិក្សាបានចូលរៀនទាំងអស់គ្នា ផ្តល់ការអប់រំបឋមសិក្សាប្រកបដោយគុណភាព និងរក្សាកុមារឱ្យរៀនចប់ភូមិសិក្សា និងបានបន្តការសិក្សាទៅភូមិសិក្សាបន្ទាប់ទៀត។

៣. អនុកម្មវិធីទី១.៣៖ ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំមធ្យមសិក្សា

គោលបំណងនៃអនុកម្មវិធី៖ ធានាការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញ ដោយពង្រីកវិសាលភាពចំណេះដឹងពីបឋមសិក្សា និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បន្តការសិក្សា។

៤. អនុកម្មវិធីទី១.៤៖ ការពង្រីកការអប់រំក្រៅប្រព័ន្ធ និងបរិយាបន្ន

គោលបំណងនៃអនុកម្មវិធី៖ លើកកម្ពស់សេវាអប់រំក្រៅប្រព័ន្ធ និងបរិយាបន្ន តាមកម្មវិធីអប់រំសម្បូរបែប គ្រប់រូបភាព ដល់ប្រជាពលរដ្ឋគ្រប់ភេទ គ្រប់វ័យ ជាពិសេសអ្នកសិក្សាមានពិការភាព កុមារជនជាតិដើមភាគតិច និងក្រុមជនជួបការលំបាក ប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងផ្តល់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នាដើម្បីចូលរួមអភិវឌ្ឍសង្គមជាតិ។

៥. អនុកម្មវិធីទី១.៥៖ ការពង្រឹង និងពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា

គោលបំណងនៃអនុកម្មវិធី៖ គ្រប់គ្រង និងអភិវឌ្ឍកម្មវិធីអប់រំសុខភាព និងអនាម័យ គ្រប់គ្រងបន្ទប់សង្គ្រោះបឋម ពិនិត្យសុខភាព និងកាយសម្បទាបុគ្គលិកអប់រំ និងអ្នកសិក្សា គ្រប់គ្រងនិងអភិវឌ្ឍកម្មវិធីទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភ ពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីលើកកម្ពស់សុខភាពសិក្សា និងការស្រាវជ្រាវ ដើម្បីលើកវិធានការបង្ការទប់ស្កាត់ជំងឺផ្សេងៗនៅតាមគ្រឹះស្ថានសិក្សា ដើម្បីរួមចំណែកលើកកម្ពស់គុណភាពអប់រំ និងផ្តល់ឱ្យអ្នកសិក្សា និងបុគ្គលិកអប់រំនូវលទ្ធភាពក្នុងការទទួលបានសុខភាពល្អ និងសុខុមាលភាព ដើម្បីក្លាយជាធនធានមនុស្សប្រកបដោយសក្តានុពល។

៦. អនុកម្មវិធីទី១.៦៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការ អនុវត្តកម្មវិធីអប់រំបច្ចេកទេស

គោលបំណងនៃអនុកម្មវិធី៖ លើកកម្ពស់ការចូលរៀន និងរក្សាសិស្សឱ្យបានគង់វង្សប្រកបដោយសមធម៌ និងបរិយាបន្ននៅមធ្យមសិក្សា។ សិស្សានុសិស្ស

មានសមត្ថភាពជំនាញវិជ្ជាជីវៈ ក្នុងការប្រកបការងារចិញ្ចឹមជីវិត និងអាចបន្តការសិក្សាយកជំនាញជាន់ខ្ពស់។ សិស្សានុសិស្សនឹងមានលទ្ធភាពជ្រើសរើសប្រភេទថ្នាក់រៀនបានសមស្របទៅនឹងសមត្ថភាព ទេពកោសល្យ និងបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន ដែលវាគឺជាផ្នែកមួយជួយជំរុញឱ្យលទ្ធផលសិក្សារបស់ពួកគេទទួលបានលទ្ធផលល្អប្រសើរ ព្រមទាំងក្លាយជាត្រីវិស័យតម្រង់ទិសអាជីពនាពេលអនាគតបានកាន់តែប្រសើរ។

**៧. អនុកម្មវិធីទី១.៧៖ ការអភិវឌ្ឍការងារបណ្តុះបណ្តាលគ្រូបង្រៀន**

គោលបំណងនៃអនុកម្មវិធី៖ ពង្រឹងប្រសិទ្ធភាពកិច្ចការបណ្តុះបណ្តាលគ្រូបង្រៀន។

**៨. អនុកម្មវិធីទី១.៨៖ ការអភិវឌ្ឍកម្មវិធីសិក្សា សម្ភារៈសិក្សា និងបណ្ណាល័យ**

គោលបំណងនៃអនុកម្មវិធី៖ លើកកម្ពស់គុណភាពអប់រំតាមរយៈការ (១) អភិវឌ្ឍកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន ឯកសារគរុកោសល្យ និងសម្ភារសិក្សា និងផ្សព្វផ្សាយ (២) ពង្រឹងសមត្ថភាពមន្ត្រីជំនាញស្តីពីកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងបណ្ណាល័យ (៣) ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីសិក្សា ការងារបណ្ណាល័យ និងការផ្គត់ផ្គង់សៀវភៅសិក្សាគោល (៤) អនុវត្តការងារបណ្ណាល័យ និងរៀបចំទិវាជាតិអំណាន (៥) ផ្គត់ផ្គង់សៀវភៅសិក្សាគោល និងសម្ភារសិក្សា។

**៩. អនុកម្មវិធីទី១.៩៖ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់ នាយកសាលា គ្រូបង្រៀន និងបុគ្គលិកអប់រំ**

គោលបំណងនៃអនុកម្មវិធី៖ ពង្រឹងការអនុវត្តប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងសមត្ថភាពបុគ្គលិកអប់រំ។

**១០. អនុកម្មវិធីទី១.១០៖ សេវាគាំទ្រការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការរបស់មន្ទីរជំនាញរាជធានី ខេត្ត**

គោលបំណងនៃអនុកម្មវិធី៖ បំពេញការងារពាក់ព័ន្ធ និងគាំទ្រដល់ការអនុវត្តកម្មវិធីលើការផ្តល់សេវាអប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងអក្ខរកម្ម ដើម្បីសម្រេចបានគោលបំណងគោលនយោបាយអប់រំ។

## កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ

**១១. អនុកម្មវិធីទី២.១៖ ការលើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា**

គោលបំណងនៃអនុកម្មវិធី៖ ការលើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តម-សិក្សា។

**១២. អនុកម្មវិធីទី២.២៖ ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា**

គោលបំណងនៃអនុកម្មវិធី៖ លើកកម្ពស់សមត្ថភាពនិស្សិតបញ្ចប់ការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រនៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលបានសរសេរបាយការណ៍ស្រាវជ្រាវ ឬនិក្ខេបបទមានការកើនឡើងជាបន្តបន្ទាប់។

**១៣. អនុកម្មវិធីទី២.៣៖ ការពង្រឹងគុណភាពអប់រំ និងស្រាវជ្រាវប្រកបដោយប្រសិទ្ធភាព**

គោលបំណងនៃអនុកម្មវិធី៖ ជាមជ្ឈមណ្ឌលបណ្តុះបណ្តាលវប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេសមួយសម្រាប់ប្រទេសជាតិ ដោយផ្សារភ្ជាប់ការងារស្រាវជ្រាវវិទ្យាសាស្ត្រមូលដ្ឋានទៅនឹងការងារផលិតកម្ម និងជីវភាពសង្គម ។

**១៤. អនុកម្មវិធីទី២.៤៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវប្រកបដោយប្រសិទ្ធភាព**

គោលបំណងនៃអនុកម្មវិធី៖ បណ្តុះបណ្តាលសិស្ស និងនិស្សិតលើជំនាញបច្ចេកទេសវិជ្ជាជីវៈ និងកម្រិតឧត្តមសិក្សា ដើម្បីឱ្យក្លាយជាអ្នកដែលមានសមត្ថភាពពេញលេញលើចំណេះដឹង ជំនាញ អត្តចរិក និងភាពថ្លៃថ្នូរ ក្នុងការឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងវប្បធម៌។

**១៥. អនុកម្មវិធីទី២.៥៖ លើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ**

គោលបំណងនៃអនុកម្មវិធី៖ លើកកម្ពស់ការបណ្តុះបណ្តាលសិស្ស និស្សិតកម្រិតឧត្តមសិក្សា និងជំនាញអប់រំ បច្ចេកទេស វិជ្ជាជីវៈឱ្យទទួលបានចំណេះដឹងសមស្របទៅតាមតម្រូវការសង្គម មានសមត្ថភាពបំពេញការងារដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

**១៦. អនុកម្មវិធីទី២.៦៖ ការអភិវឌ្ឍការបណ្តុះបណ្តាល និងស្រាវជ្រាវ**

គោលបំណងនៃអនុកម្មវិធី៖ លើកកម្ពស់ការបណ្តុះបណ្តាលលើជំនាញវិស្វកម្ម ផ្តល់ការស្រាវជ្រាវវិទ្យាសាស្ត្រនិងនវានុវត្តន៍ជាអាទិភាព និងធានាឱ្យបាននូវការផលិតធនធានមនុស្សប្រកបដោយគុណភាពខ្ពស់ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។

**១៧. អនុកម្មវិធីទី២.៧៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ**

គោលបំណងនៃអនុកម្មវិធី៖ បណ្តុះបណ្តាល និងវិក្រឹតការ គ្រូបង្រៀន អ្នកគ្រប់គ្រងអប់រំ មន្ត្រីអធិការកិច្ច និងអ្នកធ្វើផែនការអប់រំ និងអ្នកស្រាវជ្រាវវិទ្យាសាស្ត្រអប់រំ (អនុក្រឹត្យលេខ ០៤ អនក្រ.បក-១៣.០៣.២០០៤)។

**១៨. អនុកម្មវិធីទី២.៨៖ ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ**

គោលបំណងនៃអនុកម្មវិធី៖ ផលិតនិស្សិតស្របតាមតម្រូវទីផ្សារការងារ និងការស្រាវជ្រាវសម្រាប់ការអភិវឌ្ឍ។

**១៩. អនុកម្មវិធីទី២.៩៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ**

គោលបំណងនៃអនុកម្មវិធី៖ លើកកម្ពស់ការបណ្តុះបណ្តាលធនធានមនុស្ស ស្រាវជ្រាវវប្បធម៌ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។

**២០. អនុកម្មវិធីទី២.១០៖ ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវ**

គោលបំណងនៃអនុកម្មវិធី៖ បណ្តុះបណ្តាលនិស្សិតប្រកបដោយគុណភាព ប្រសិទ្ធភាព និងទទួលបានការងារធ្វើក្រោយបញ្ចប់ការសិក្សា។ បង្កើនបុគ្គលិកអប់រំមានគុណវុឌ្ឍិ អាចផ្តល់ចំណេះដឹង ចំណេះធ្វើ និងបំណិនដល់និស្សិត។

**២១. អនុកម្មវិធីទី២.១១៖ លើកកម្ពស់គុណភាពបណ្តុះបណ្តាល ស្រាវជ្រាវ និងសហគ្រិនភាព**

គោលបំណងនៃអនុកម្មវិធី៖ ពង្រឹងគុណភាពបណ្តុះបណ្តាលធនធានមនុស្សឆ្លើយតបនឹងតម្រូវការទីផ្សារការងារនិងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចក្នុងបរិបទបរិវត្តកម្មឌីជីថល និងលើកកម្ពស់ការស្រាវជ្រាវ នវានុវត្តន៍ និងសហគ្រិនភាព

**២២. អនុកម្មវិធីទី២.១២៖ ការពង្រឹងគុណភាពប្រសិទ្ធភាពអប់រំ និងការស្រាវជ្រាវ**

គោលបំណងនៃអនុកម្មវិធី៖ អភិវឌ្ឍសមត្ថភាពធនធានមនុស្សក្នុងបរិបទបរិវត្តកម្មឌីជីថល លើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍។

**២៣. អនុកម្មវិធីទី២.១៣៖ ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា**

គោលបំណងនៃអនុកម្មវិធី៖ ការលើកកម្ពស់គុណភាពអប់រំឧត្តមសិក្សាដោយផ្អែកលើស្តង់ដាជាតិ តំបន់ និងអន្តរជាតិ។

**២៤. អនុកម្មវិធីទី២.១៤៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវលើមុខជំនាញ STEAM ។**

គោលបំណងនៃអនុកម្មវិធី៖ ពង្រឹងគុណភាពនិងប្រសិទ្ធភាពការបណ្តុះបណ្តាល និងការស្រាវជ្រាវ។

**២៥. អនុកម្មវិធីទី២.១៥៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ**

គោលបំណងនៃអនុកម្មវិធី៖ ផ្តល់ការអប់រំបណ្តុះបណ្តាលជំនាញផ្នែកក្សេត្រសាស្ត្រ (ដាំដុះ ដំណាំ ដី ការពារដំណាំ) បច្ចេកវិទ្យា (វារីវប្បកម្ម សេនេទិច និងបង្កាត់ពូជ ចំណី) និងកសិឧស្សាហកម្ម (ចំណីអាហារ និងអាហារូបត្ថម្ភ ចំណីអាហារ បច្ចេកទេសប្រមូលផល) និងការគ្រប់គ្រងអាជីវកម្ម ដែលផ្សារភ្ជាប់នូវអន្តរសកម្មរវាងវិចារណញាណពុទ្ធិជាមួយនឹងករណពុទ្ធិ ដែលជាជំនាញចាំបាច់ស្របតាមតម្រូវការទីផ្សារការងារ និងក្នុងការអភិវឌ្ឍប្រទេសជាតិយូរអង្វែង ជាពិសេសនៅតាមតំបន់ភូមិភាគឦសាន។

២៦. អនុកម្មវិធីទី២.១៦៖ ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងការស្រាវជ្រាវលើផ្នែកបច្ចេកទេសវិជ្ជាជីវៈ

គោលបំណងនៃអនុកម្មវិធី៖ បណ្ដុះបណ្ដាលជំនាញអប់រំបច្ចេកទេសកម្រិតមធ្យម និងកម្រិតឧត្ដម ការអភិវឌ្ឍ និងការអនុវត្តកម្មវិធីសិក្សាស្របតាមតម្រូវការទីផ្សារការងារ និងក្របខណ្ឌគុណវុឌ្ឍិជាតិ និងកសាងសមត្ថភាពដល់បុគ្គលិកវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ តាមរយៈការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ការស្រាវជ្រាវ និងការពង្រឹងកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ។

២៧. អនុកម្មវិធីទី២.១៧៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំគ្រូបង្រៀនឆ្លើយស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ

គោលបំណងនៃអនុកម្មវិធី៖ លើកកម្ពស់សមត្ថភាពគ្រូបង្រៀនឱ្យមានគុណសម្បទាពេញលេញឆ្លើយតបនឹងបំណិន សតវត្សរ៍ទី២១ និងការអប់រំឌីជីថល តាមរយៈកម្មវិធីអប់រំគ្រូបង្រៀនដំបូង កម្មវិធីវិក្រឹតការគ្រូបង្រៀន និងការស្រាវជ្រាវអប់រំ។

២៨. អនុកម្មវិធីទី២.១៨៖ ពង្រឹងគុណភាពបណ្ដុះបណ្ដាល វិក្រឹតការគ្រូ និងការស្រាវជ្រាវ ស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ

គោលបំណងនៃអនុកម្មវិធី៖ ពង្រឹងគុណភាពបណ្ដុះបណ្ដាលវិក្រឹតការគ្រូ និងការស្រាវជ្រាវស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ។

កម្មវិធីទី៣៖ ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា

២៩. អនុកម្មវិធីទី៣.១៖ ការអភិវឌ្ឍកីឡាមហាជន

គោលបំណងនៃអនុកម្មវិធី៖ ប្រជាជនមានសុខភាពល្អ រួមចំណែកលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ រស់នៅប្រកបដោយសុខដុមនីយកម្ម។

៣០. អនុកម្មវិធីទី៣.២៖ ការអភិវឌ្ឍអប់រំកាយ និងកីឡាសិស្ស-និស្សិត

គោលបំណងនៃអនុកម្មវិធី៖ ជួសជុល ថែទាំ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធកីឡា និងបំពាក់សម្ភារបរិក្ខារកីឡា អភិវឌ្ឍន៍សកម្មភាពអប់រំកាយ ក្នុងម៉ោងសិក្សា និងកីឡាក្រៅម៉ោងសិក្សា ដើម្បីទទួលបានសុខភាពផ្លូវកាយ និងផ្លូវចិត្តដល់សិស្សានុសិស្សប្រកបដោយគុណភាពនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន។

៣១. អនុកម្មវិធីទី៣.៣៖ ការបណ្ដុះបណ្ដាលធនធានមនុស្សផ្នែកអប់រំកាយ និងកីឡា

គោលបំណងនៃអនុកម្មវិធី៖ បណ្ដុះបណ្ដាល និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអប់រំកាយ និងកីឡា។

**៣២. អនុកម្មវិធីទី៣.៤៖ ការអភិវឌ្ឍកីឡាកម្រិតខ្ពស់**

គោលបំណងនៃអនុកម្មវិធី៖ បង្កើនគុណផលកីឡាករថ្នាល និងកីឡាករជម្រើសជាតិសម្រាប់ចូលរួមប្រកួតកីឡាស៊ីហ្គេមនិងប្រកួតកីឡាជាលក្ខណៈអន្តរជាតិ។

**៣៣. អនុកម្មវិធីទី៣.៥៖ អភិវឌ្ឍន៍ការរៀបចំព្រឹត្តិការណ៍កីឡាគ្រប់កម្រិត និងចងក្រងស្ថិតិកីឡា**

គោលបំណងនៃអនុកម្មវិធី៖ បង្កើនសមត្ថភាពមន្ត្រីបច្ចេកទេស គ្រូបង្វឹក និងការជ្រើសរើសអត្តពលិក ដើម្បីសិក្សា ស្រាវជ្រាវ វាយតម្លៃគុណផលកីឡា ចងក្រង និងផ្សព្វផ្សាយ។

**៣៤. អនុកម្មវិធីទី៣.៧៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងពហុកីឡដ្ឋានជាតិ**

គោលបំណងនៃអនុកម្មវិធី៖ ពង្រឹងការប្រើប្រាស់ទីលានកីឡា និងទីធ្លាសម្រាប់ទ្រទ្រង់ពហុ-កីឡដ្ឋាន និងសម្រាប់សុខុមាលភាពសង្គម។

**៣៥. អនុកម្មវិធីទី៣.៨៖ សេវាគាំទ្រការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡារបស់មន្ទីរជំនាញរាជធានី ខេត្ត**

គោលបំណងនៃអនុកម្មវិធី៖ បំពេញការងារពាក់ព័ន្ធ និងគាំទ្រដល់ការអនុវត្តកម្មវិធីលើវិស័យអប់រំកាយ និងកីឡា សុខុមាលភាពប្រជាពលរដ្ឋ និងការប្រកួតកីឡាដើម្បីសម្រេចបានគោលបំណងគោលនយោបាយអប់រំ។

**កម្មវិធីទី៤៖ ការអភិវឌ្ឍយុវជន**

**៣៦. អនុកម្មវិធីទី៤.១៖ ការអភិវឌ្ឍសកម្មភាពយុវជន**

គោលបំណងនៃអនុកម្មវិធី៖ អប់រំឱ្យយុវជនធ្វើការងារក្រុម ចេះរួមរស់ជាមួយគ្នា ស្រឡាញ់វប្បធម៌ បរិស្ថាន មានលក្ខណៈសហគ្រិនភាព និងមោទកភាពជាតិ ជំរុញឱ្យសកម្មភាពក្លឹប ក្រុមប្រឹក្សាកុមារនិងយុវជន ដំណើរការពេញលេញនៅតាមគ្រឹះស្ថានសិក្សា និងលើកកម្ពស់ការផ្លាស់ប្តូរបទពិសោធន៍ និងពង្រឹងទំនាក់ទំនងរវាងយុវជនក្នុងតំបន់និងលើសាកលលោក ហើយចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍប្រទេសជាតិ ដោយការផ្សារភ្ជាប់ទ្រឹស្តីនិងសង្គមជាក់ស្តែង ដើម្បីឆ្លើយតបតាមតម្រូវការចាំបាច់របស់យុវជន។

**៣៧. អនុកម្មវិធីទី៤.២៖ ការអភិវឌ្ឍមជ្ឈមណ្ឌលយុវជន**

គោលបំណងនៃអនុកម្មវិធី៖ យុវជនមានចំណេះដឹង សមត្ថភាព សេចក្តីក្លាហាន លក្ខណៈសម្បត្តិគ្រប់គ្រាន់ពេញលេញទាំងផ្លូវកាយនិងផ្លូវចិត្ត មានជំនាញអាចបង្កើតអាជីវកម្មដោយខ្លួនឯង និងបន្តការសិក្សាក្រៅប្រព័ន្ធដើម្បីកាត់បន្ថយភាពក្រីក្រ រួមកសាងការពារប្រទេសជាតិ។

**៣៨. អនុកម្មវិធីទី៤.៣៖ ការអភិវឌ្ឍកាយរឹទ្ធិកម្ម**

គោលបំណងនៃអនុកម្មវិធី៖ រួមចំណែកក្នុងការអភិវឌ្ឍកុមារ និងយុវជនឱ្យមានសក្តានុពល-ភាពពេញលេញខាងផ្លូវកាយ ផ្លូវបញ្ញា ផ្លូវសង្គម ផ្លូវចិត្ត និងផ្លូវ

អារម្មណ៍ ដើម្បីឱ្យក្លាយទៅជាពលរដ្ឋមានទំនួលខុសត្រូវ និងទៅជាសមាជិកក្នុងសហគមន៍តាមមូលដ្ឋានរស់នៅសហគមន៍ជាតិ និងសហគមន៍អន្តរជាតិ។

**៣៩. អនុកម្មវិធីទី៤.៤៖ សេវាគាំទ្រការអភិវឌ្ឍយុវជនរបស់មន្ទីរជំនាញរាជធានី ខេត្ត**

គោលបំណងនៃអនុកម្មវិធី៖ បំពេញការងារពាក់ព័ន្ធ និងគាំទ្រដល់ការអនុវត្តកម្មវិធីលើការអនុវត្តគោលនយោបាយជាតិនិងផែនការយុទ្ធសាស្រ្ត ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ដើម្បីសម្រេចបានគោលបំណងគោលនយោបាយអប់រំ។

**កម្មវិធីទី៥៖ ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ**

**៤០. អនុកម្មវិធីទី៥.១៖ ការអភិវឌ្ឍ និងពង្រឹងប្រព័ន្ធផែនការអប់រំ**

គោលបំណងនៃអនុកម្មវិធី៖ ធានាកសាងបានប្រព័ន្ធផែនការច្បាស់លាស់និងស៊ីសង្វាក់គ្នានៅគ្រប់លំដាប់ថ្នាក់ និងការអនុវត្តប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅគ្រប់លំដាប់ថ្នាក់។

**៤១. អនុកម្មវិធីទី៥.២៖ ការគ្រប់គ្រង និងពង្រឹងប្រសិទ្ធភាពធនធានមនុស្ស**

គោលបំណងនៃអនុកម្មវិធី៖ គ្រប់គ្រងក្របខណ្ឌ ការងាររដ្ឋបាល បុគ្គលិកអប់រំ និងភ្នាក់ងាររាជការរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានទំនាក់ទំនងជាមួយក្រសួងមុខងារសាធារណៈ និងវាយតម្លៃតម្រូវការបណ្តុះបណ្តាលបុគ្គលិកអប់រំ។

**៤២. អនុកម្មវិធីទី៥.៣៖ ការគ្រប់គ្រងហិរញ្ញវត្ថុ ការអភិវឌ្ឍសមត្ថភាព ការគាំទ្រការលើកកម្ពស់គុណភាពអប់រំនិងមូលដ្ឋានសម្ភារៈ**

គោលបំណងនៃអនុកម្មវិធី៖ ដឹកនាំ ណែនាំ គាំទ្រ និងសម្របសម្រួលជាមួយអង្គភាពថវិការួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងការរៀបចំថវិកា ការអនុវត្តថវិកា ការសិក្សានិងវិភាគថវិកា ការពិនិត្យនិងតាមដានការអនុវត្តថវិកា និងបូកសរុបរបាយការណ៍គ្រប់ប្រភេទថវិកា ព្រមទាំងលើកកម្ពស់សមត្ថភាពមន្ត្រីជំនាញ និងកសាងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុស្របតាមនវានុវត្តន៍នៃកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិស័យអប់រំ។

**៤៣. អនុកម្មវិធីទី៥.៤៖ ការពង្រឹងការងារសវនកម្មផ្ទៃក្នុង**

គោលបំណងនៃអនុកម្មវិធី៖ ផ្តល់ប្រឹក្សាជូនដល់ប្រធានសវនដ្ឋាន (អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា) លើគ្រប់បញ្ហាទាក់ទងនឹងការគ្រប់គ្រង និងប្រតិបត្តិការ និងជួយឱ្យសវនដ្ឋានបំពេញការទទួលខុសត្រូវ

ប្រកបដោយប្រសិទ្ធភាព ហើយកិច្ចការនេះអាចធ្វើបានតាមរយៈផ្តល់ជូននូវរបាយការណ៍ដែលមានការវិភាគដោយឯករាជ្យ ការវាយតម្លៃអនុសាសន៍ និងការកត់សម្គាល់ពាក់ព័ន្ធនឹងសកម្មភាពដែលត្រូវបានធ្វើសវនកម្ម។ ដើម្បីសម្រេចនូវគោលបំណងទាំងនេះ មន្ត្រីសវនកម្មត្រូវបំពេញការងារប្រកបដោយជំនាញវិជ្ជាជីវៈជាអាទិភាពជំនាញ ការគាំពារវិជ្ជាជីវៈ និងការបន្តអភិវឌ្ឍវិជ្ជាជីវៈ។

**៤៤. អនុកម្មវិធីទី៥.៥៖ ការពិនិត្យតាមដាន វាយតម្លៃ និងអធិការកិច្ចប្រព័ន្ធធានាគុណភាពអប់រំ**

គោលបំណងនៃអនុកម្មវិធី៖ វាយតម្លៃគុណភាពអប់រំធៀបនឹងស្តង់ដាអប់រំជាតិ តំបន់ និងអន្តរជាតិ ដែលជាលក្ខណៈការវាយតម្លៃអប់រំបែបបរិមាណវិស័យ ព្រមទាំងរកឱ្យឃើញពីកត្តាដែលជះឥទ្ធិពលដល់គុណភាពអប់រំនៅកម្ពុជា ដែលជាការស្រាវជ្រាវអប់រំបែបគុណវិស័យ។

**៤៥. អនុកម្មវិធីទី៥.៦៖ អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ**

គោលបំណងនៃអនុកម្មវិធី៖ ការងារគ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងវិស័យអប់រំកាន់តែមានប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព។

**៤៦. អនុកម្មវិធីទី៥.៧៖ លើកកម្ពស់ និងអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិលើវិស័យអប់រំ**

គោលបំណងនៃអនុកម្មវិធី៖ លើកកម្ពស់វិស័យអប់រំតាមរយៈកិច្ចសហប្រតិបត្តិការជាតិ អន្តរ-ជាតិ និងដៃគូអភិវឌ្ឍន៍។

**៤៧. អនុកម្មវិធីទី៥.៨៖ ការពង្រឹងការងារនីតិកម្ម**

គោលបំណងនៃអនុកម្មវិធី៖ ពង្រឹងការងារនីតិកម្មវិស័យអប់រំ។

**៤៨. អនុកម្មវិធីទី៥.៩៖ ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធអប់រំ**

គោលបំណងនៃអនុកម្មវិធី៖ ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធអប់រំប្រកបដោយប្រសិទ្ធភាព និងគុណភាព។

**៤៩. អនុកម្មវិធីទី៥.១១៖ ការអភិវឌ្ឍ និងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រង និងការធានាស័ក្តិសិទ្ធិភាពនៃសេវារដ្ឋបាល**

គោលបំណងនៃអនុកម្មវិធី៖ សេវារដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទទួលបានការចូលរួមសន្និបាតអប់រំ និងលើកទិសដៅឆ្នាំបន្តបន្ទាប់ ហើយចូលរួមពិធីប្រតិទិនការងារដូចជា បុណ្យមាឃបូជា វិសាខបូជា....។ល។ នាយកដ្ឋានជាអ្នកទទួលបន្ទុកលើការងារបណ្ណសារអប់រំទាំងមូល និងលើកទឹកចិត្តបុគ្គលិកអប់រំឆ្នើម ដោយការបំពាក់គ្រឿងឥស្សរិយយសពីថ្នាក់ដឹកនាំក្រសួង និងការគ្រប់គ្រងទីស្តីការក្រសួង។

**៥០. អនុកម្មវិធីទី៥.១៣៖ ការអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ**

គោលបំណងនៃអនុកម្មវិធី៖ អភិវឌ្ឍន៍សមត្ថភាព និងលើកកម្ពស់គុណភាព ប្រសិទ្ធភាពនៃការកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ស្ថិតិ និងសូចនាករអប់រំ។

**៥១. អនុកម្មវិធីទី៥.១៤៖ ការស្រាវជ្រាវ និងអភិវឌ្ឍន៍គោលនយោបាយអប់រំ**

គោលបំណងនៃអនុកម្មវិធី៖ អភិវឌ្ឍន៍គោលនយោបាយអប់រំ យុវជន និងកីឡា ផ្អែកលើការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ការពិនិត្យតាមដានវាយតម្លៃការអនុវត្តគោលនយោបាយអប់រំ យុវជន និងកីឡា ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍ និងអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងបុគ្គលិកអប់រំនៅគ្រប់កម្រិតថ្នាក់។

**៥២. អនុកម្មវិធីទី៥.១៥៖ ការអភិវឌ្ឍ និងពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ**

គោលបំណងនៃអនុកម្មវិធី៖ ធានាការអនុវត្តគោលនយោបាយ ផែនការ កម្មវិធី និងគម្រោងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡាប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងដើម្បីសម្រេចឱ្យបាននូវគោលបំណងគោលនយោបាយអប់រំ។

**៥៣. អនុកម្មវិធីទី៥.១៦៖ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានសម្រាប់ការងារអប់រំ យុវជន និងកីឡា**

គោលបំណងនៃអនុកម្មវិធី៖ លើកកម្ពស់ការអប់រំមិនផ្លូវការ (E-Learning) ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ICT តភ្ជាប់បណ្តាញ Network និងអ៊ីនធឺណិត លើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានអេឡិចត្រូនិក តាមរយៈការផលិតមាតិកា និងព័ត៌មានអប់រំឌីជីថលសម្បូរបែប។ កិច្ចដំណើរការប្រព្រឹត្តទៅរបស់អង្គភាព សម្របសម្រួលកិច្ចសហការប្រតិបត្តិការភាពជាដៃគូ ការកសាងសមត្ថភាពវិជ្ជាជីវៈមន្ត្រីអប់រំ គ្រូបង្រៀន គរុសិស្ស-និស្សិត ពិនិត្យតាមដានវាយតម្លៃការរៀបចំ និងថែទាំស្ទូឌីយូពហុមេឌៀអប់រំ បម្រើដល់ការផលិតមាតិកាអប់រំឌីជីថល និងការអភិវឌ្ឍមជ្ឈមណ្ឌលម៉ាស៊ីនបម្រើទិន្នន័យអប់រំរួមរបស់ក្រសួង។

**៥៤. អនុកម្មវិធីទី៥.១៧៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពការងារប្រឡងនៅមធ្យមសិក្សា និងអប់រំបច្ចេកទេស**

គោលបំណងនៃអនុកម្មវិធី៖ ធានាបាននូវការប្រឡងនៅមធ្យមសិក្សា និងអប់រំបច្ចេកទេសប្រព្រឹត្តទៅស្របតាមគោលការណ៍ច្បាប់ យុត្តិធម៌ តម្លាភាព និងលទ្ធផលទទួលយកបាន។

**៥៥. អនុកម្មវិធីទី៥.១៨៖ សេវាគាំទ្រការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អរបស់មន្ទីរជំនាញរាជធានី ខេត្ត**

គោលបំណងនៃអនុកម្មវិធី៖ បំពេញការងារពាក់ព័ន្ធ និងគាំទ្រដល់ការអនុវត្តកម្មវិធីលើការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផលការងារវិមជ្ឈការ និងវិសហមជ្ឈការ និងការបង្កើតភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ដើម្បីសម្រេចបានគោលបំណងគោលនយោបាយអប់រំ។

| កម្មវិធី អនុកម្មវិធី អ្នកគ្រប់គ្រង និងអង្គភាពទទួលខុសត្រូវ | | | | | | |
|---|---|---|---|---|---|---|
| គោលបំណង គោលនយោបាយ | ឈ្មោះកម្មវិធី និងអនុកម្មវិធី | អ្នកគ្រប់គ្រង | អង្គភាពទទួលខុសត្រូវ | | | |
| | | | ឈ្មោះអង្គភាព | (១) | (២) | (៣) |
| ធានាឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត | **កម្មវិធីទី១៖ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ** | **អគ្គនាយក** | **អគ្គនាយកដ្ឋានអប់រំ** | ✓ | | |
| | អនុកម្មវិធីទី១.១៖ ការពង្រីកការអប់រំកុមារតូច | ប្រធាននាយកដ្ឋាន | នាយកដ្ឋានអប់រំកុមារតូច | | ✓ | |
| | អនុកម្មវិធីទី១.២៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា | ប្រធាននាយកដ្ឋាន | នាយកដ្ឋានបឋមសិក្សា | | ✓ | |
| | អនុកម្មវិធីទី១.៣៖ ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា | ប្រធាននាយកដ្ឋាន | នា.មធ្យមសិក្សានិងចំណេះទូទៅ | | ✓ | |
| | អនុកម្មវិធីទី១.៤៖ ការពង្រីកការអប់រំក្រៅប្រព័ន្ធនិងបរិយាបន្ន | ប្រធាននាយកដ្ឋាន | នា.អប់រំក្រៅប្រព័ន្ធនិងបរិយាបន្ន | | ✓ | |
| | អនុកម្មវិធីទី១.៥៖ ការពង្រឹងនិងពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា | ប្រធាននាយកដ្ឋាន | នាយកដ្ឋានសុខភាពសិក្សា | | ✓ | |
| | អនុកម្មវិធីទី១.៦៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស | ប្រធាននាយកដ្ឋាន | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | | ✓ | |
| | អនុកម្មវិធីទី១.៧៖ ការអភិវឌ្ឍការងារ បណ្តុះបណ្តាលគ្រូបង្រៀន | ប្រធាននាយកដ្ឋាន | នាយកដ្ឋានកិច្ចការបណ្តុះបណ្តាល | | | ✓ |
| | អនុកម្មវិធីទី១.៨៖ ការអភិវឌ្ឍកម្មវិធីសិក្សា សម្ភារៈសិក្សា និងបណ្ណាល័យ | ប្រធាននាយកដ្ឋាន | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | | ✓ | |
| | អនុកម្មវិធីទី១.៩៖ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់នាយកសាលា គ្រូបង្រៀន និងបុគ្គលិកអប់រំ | ប្រធាននាយកដ្ឋាន | នាយកដ្ឋានកិច្ចការវិក្រឹតការ | | | ✓ |
| | អនុកម្មវិធីទី១.១០៖ សេវាគាំទ្រការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការរបស់មន្ទីរជំនាញរាជធានី ខេត្ត | អគ្គលេខាធិការ | មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | ✓ | | |
| | **កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ** | **អគ្គនាយក** | **អគ្គនាយកដ្ឋានឧត្តមសិក្សា** | | | |
| | អនុកម្មវិធីទី២.១៖ ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា | ប្រធាននាយកដ្ឋាន | នាយកដ្ឋានគ្រប់គ្រងឧត្តមសិក្សា | | ✓ | |
| | អនុកម្មវិធីទី២.២៖ ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា | ប្រធាននាយកដ្ឋាន | នាយកដ្ឋានស្រាវជ្រាវនិងនវានុវត្តន៍ | | ✓ | |
| | អនុកម្មវិធីទី២.៣៖ ការពង្រឹងគុណភាពអប់រំ និងស្រាវជ្រាវប្រកបដោយប្រសិទ្ធភាព | សាកលវិទ្យាធិការ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ✓ | | |

| កម្មវិធី អនុកម្មវិធី អ្នកគ្រប់គ្រង និងអង្គភាពទទួលខុសត្រូវ | | | | | | |
|---|---|---|---|---|---|---|
| **គោលបំណងគោលនយោបាយ** | **ឈ្មោះកម្មវិធី និងអនុកម្មវិធី** | **អ្នកគ្រប់គ្រង** | **អង្គភាពទទួលខុសត្រូវ** | | | |
| | | | **ឈ្មោះអង្គភាព** | **(១)** | **(២)** | **(៣)** |
| | អនុកម្មវិធីទី២.៤៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវប្រកបដោយប្រសិទ្ធភាព | សាកលវិទ្យាធិការ | សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ | | ✓ | |
| | អនុកម្មវិធីទី២.៥៖ លើកកម្ពស់គុណភាព នៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ | សាកលវិទ្យាធិការ | សា. ជាតិ ជា ស៊ីម កំចាយមារ | ✓ | | |
| | អនុកម្មវិធីទី២.៦៖ ការអភិវឌ្ឍការបណ្តុះបណ្តាល និងស្រាវជ្រាវ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ✓ | | |
| | អនុកម្មវិធីទី២.៧៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានជាតិអប់រំ | ✓ | | |
| | អនុកម្មវិធីទី២.៨៖ ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យស្វាយរៀង | ✓ | | |
| | អនុកម្មវិធីទី២.៩៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យជាតិមានជ័យ | ✓ | | |
| | អនុកម្មវិធីទី២.១០៖ ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យជាតិបាត់ដំបង | ✓ | | |
| | អនុកម្មវិធីទី២.១១៖ លើកកម្ពស់គុណភាពបណ្តុះបណ្តាល ស្រាវជ្រាវ និងសហគ្រិនភាព | សាកលវិទ្យាធិការ | សាកលវិទ្យាល័យជាតិគ្រប់គ្រង | ✓ | | |
| | អនុកម្មវិធីទី២.១២៖ ការពង្រឹងគុណភាពប្រសិទ្ធភាពអប់រំ និងការស្រាវជ្រាវ | សាកលវិទ្យាធិការ | សា.ភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច | ✓ | | |
| | អនុកម្មវិធីទី២.១៣៖ ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា | អគ្គលេខាធិការ | គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | ✓ | | |
| | អនុកម្មវិធីទី២.១៤៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវលើមុខជំនាញ STEAM ។ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | ✓ | | |
| | អនុកម្មវិធីទី២.១៥៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យក្រចេះ | | ✓ | |
| | អនុកម្មវិធីទី២.១៦៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពអប់រំ និងការស្រាវជ្រាវលើផ្នែកបច្ចេកទេសវិជ្ជាជីវៈ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ | ✓ | | |
| | អនុកម្មវិធីទី២.១៧៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំគ្រូបង្រៀនឆ្លើយស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | | ✓ | |
| | អនុកម្មវិធីទី២.១៨៖ ពង្រឹងគុណភាពបណ្តុះបណ្តាល វិក្រឹតការគ្រូ និងការស្រាវជ្រាវ ស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានគរុកោសល្យបាត់ដំបង | | ✓ | |

| កម្មវិធី អនុកម្មវិធី អ្នកគ្រប់គ្រង និងអង្គភាពទទួលខុសត្រូវ | | | | | | |
|---|---|---|---|---|---|---|
| គោលបំណងគោលនយោបាយ | ឈ្មោះកម្មវិធី និងអនុកម្មវិធី | អ្នកគ្រប់គ្រង | អង្គភាពទទួលខុសត្រូវ | | | |
| | | | ឈ្មោះអង្គភាព | (១) | (២) | (៣) |
| | **កម្មវិធីទី៣៖ ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា** | **អគ្គនាយក** | **អគ្គនាយកដ្ឋានកីឡា** | ✓ | | |
| | អនុកម្មវិធីទី៣.១៖ ការអភិវឌ្ឍកីឡាមហាជន | ប្រធាននាយកដ្ឋាន | នា. កីឡាជំនាញនិងកីឡាមហាជន | | | ✓ |
| | អនុកម្មវិធីទី៣.២៖ ការអភិវឌ្ឍអប់រំកាយ និងកីឡាសិស្ស-និស្សិត | ប្រធាននាយកដ្ឋាន | នា. អប់រំកាយ និងកីឡាសិស្ស និស្សិត | | | ✓ |
| | អនុកម្មវិធីទី៣.៣៖ ការបណ្តុះបណ្តាលធនធានមនុស្សផ្នែកអប់រំកាយ និងកីឡា | នាយកវិទ្យាស្ថាន | វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា | | | ✓ |
| | អនុកម្មវិធីទី៣.៤៖ ការអភិវឌ្ឍកីឡាកម្រិតខ្ពស់ | ប្រធានមជ្ឈមណ្ឌល | មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | | | ✓ |
| | អនុកម្មវិធីទី៣.៥៖ អភិវឌ្ឍការរៀបចំព្រឹត្តិការណ៍កីឡាគ្រប់កម្រិត និងចងក្រងស្ថិតិកីឡា | ប្រធាននាយកដ្ឋាន | នា.រៀបចំព្រឹត្តិការណ៍និងស្ថិតិកីឡា | | | ✓ |
| | អនុកម្មវិធីទី៣.៧៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងពហុកីឡដ្ឋានជាតិ | ប្រធានពហុកីឡដ្ឋាន | ពហុកីឡដ្ឋានជាតិ | ✓ | | |
| | អនុកម្មវិធីទី៣.៨៖ សេវាគាំទ្រការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡារបស់មន្ទីរជំនាញរាជធានី ខេត្ត | អគ្គលេខាធិការ | មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | ✓ | | |
| | **កម្មវិធីទី៤៖ ការអភិវឌ្ឍយុវជន** | **អគ្គនាយក** | **អគ្គនាយកដ្ឋានយុវជន** | ✓ | | |
| | អនុកម្មវិធីទី៤.១៖ ការអភិវឌ្ឍសកម្មភាពយុវជន | ប្រធាននាយកដ្ឋាន | នាយកដ្ឋានអប់រំយុវជននិងកុមារ | | | ✓ |
| | អនុកម្មវិធីទី៤.២៖ ការអភិវឌ្ឍមជ្ឈមណ្ឌលយុវជន | ប្រធាននាយកដ្ឋាន | នាយកដ្ឋានអភិវឌ្ឍកម្មវិធីយុវជន | | | ✓ |
| | អនុកម្មវិធីទី៤.៣៖ ការអភិវឌ្ឍកាយរឹទ្ធិកម្ម | ប្រធាននាយកដ្ឋាន | នាយកដ្ឋានសហប្រតិបត្តិការកាយរឹទ្ធិ | | | ✓ |
| | អនុកម្មវិធីទី៤.៤៖ សេវាគាំទ្រការអភិវឌ្ឍយុវជនរបស់មន្ទីរជំនាញរាជធានី ខេត្ត | អគ្គលេខាធិការ | មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | ✓ | | |
| | **កម្មវិធីទី៥៖ ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ** | **អគ្គលេខាធិការ** | **អគ្គលេខាធិការដ្ឋាន** | ✓ | | |
| | អនុកម្មវិធីទី៥.១៖ ការអភិវឌ្ឍ និងពង្រឹងប្រព័ន្ធផែនការអប់រំ | ប្រធាននាយកដ្ឋាន | នាយកដ្ឋានផែនការ | | | ✓ |
| | អនុកម្មវិធីទី៥.២៖ ការគ្រប់គ្រង និងពង្រឹងប្រសិទ្ធភាពធនធានមនុស្ស | ប្រធាននាយកដ្ឋាន | នាយកដ្ឋានធនធានមនុស្ស | | | ✓ |
| | អនុកម្មវិធីទី៥.៣៖ ការគ្រប់គ្រងហិរញ្ញវត្ថុ ការអភិវឌ្ឍសមត្ថភាព ការគាំទ្រការលើកកម្ពស់គុណភាពអប់រំ និងមូលដ្ឋានសម្ភារៈ | ប្រធាននាយកដ្ឋាន | នាយកដ្ឋានហិរញ្ញវត្ថុ | | | ✓ |
| | អនុកម្មវិធីទី៥.៤៖ ការពង្រឹងការងារសវនកម្មផ្ទៃក្នុង | ប្រធាននាយកដ្ឋាន | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | | ✓ | |

| កម្មវិធី អនុកម្មវិធី អ្នកគ្រប់គ្រង និងអង្គភាពទទួលខុសត្រូវ | | | | | | |
|---|---|---|---|---|---|---|
| គោលបំណង គោលនយោបាយ | ឈ្មោះកម្មវិធី និងអនុកម្មវិធី | អ្នកគ្រប់គ្រង | អង្គភាពទទួលខុសត្រូវ | | | |
| | | | ឈ្មោះអង្គភាព | (១) | (២) | (៣) |
| | អនុកម្មវិធីទី៥.៥៖ ការពិនិត្យតាមដាន វាយតម្លៃ និងអធិការកិច្ចប្រព័ន្ធធានាគុណភាពអប់រំ | ប្រធាននាយកដ្ឋាន | នាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ | | ✓ | |
| | អនុកម្មវិធីទី៥.៦៖ អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ | ប្រធាននាយកដ្ឋាន | នាយកដ្ឋានអធិការកិច្ចនិងបណ្តឹងតវ៉ា | | ✓ | |
| | អនុកម្មវិធីទី៥.៧៖ លើកកម្ពស់និងអភិវឌ្ឍកិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិលើវិស័យអប់រំ | ប្រធាននាយកដ្ឋាន | នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងកិច្ចការអាស៊ាន | | | ✓ |
| | អនុកម្មវិធីទី៥.៨៖ ការពង្រឹងការងារនីតិកម្ម | ប្រធាននាយកដ្ឋាន | នាយកដ្ឋាននីតិកម្ម | | | ✓ |
| | អនុកម្មវិធីទី៥.៩៖ ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធអប់រំ | ប្រធាននាយកដ្ឋាន | នា.ទ្រព្យសម្បត្តិរដ្ឋនិងសំណង់ | | | ✓ |
| | អនុកម្មវិធីទី៥.១១៖ ការអភិវឌ្ឍ និងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រង និងការធានាភាពស័ក្តិសិទ្ធនៃសេវារដ្ឋបាល | ប្រធាននាយកដ្ឋាន | នាយកដ្ឋានរដ្ឋបាល | | | ✓ |
| | អនុកម្មវិធីទី៥.១៣៖ ការអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | ប្រធាននាយកដ្ឋាន | នា.ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | | | ✓ |
| | អនុកម្មវិធីទី៥.១៤៖ ការស្រាវជ្រាវ និងអភិវឌ្ឍគោលនយោបាយអប់រំ | ប្រធាននាយកដ្ឋាន | នាយកដ្ឋានគោលនយោបាយ | | | ✓ |
| | អនុកម្មវិធីទី៥.១៥៖ ការអភិវឌ្ឍនិងពង្រឹងប្រព័ន្ធពិនិត្យ តាមដាន និងវាយតម្លៃ | ប្រធាននាយកដ្ឋាន | នា.ពិនិត្យតាមដាន និងវាយតម្លៃ | | | ✓ |
| | អនុកម្មវិធីទី៥.១៦៖ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានសម្រាប់ការងារអប់រំ យុវជន និងកីឡា | ប្រធាននាយកដ្ឋាន | នាយកដ្ឋានបរិវត្តកម្មឌីជីថល | | | ✓ |
| | អនុកម្មវិធីទី៥.១៧៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពការងារប្រឡងនៅមធ្យមសិក្សា និងអប់រំបច្ចេកទេស | ប្រធាននាយកដ្ឋាន | នាយកដ្ឋានកិច្ចការប្រឡង | | | ✓ |
| | អនុកម្មវិធីទី៥.១៨៖ សេវាគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ របស់មន្ទីររាជធានី ខេត្ត | អគ្គលេខាធិការ | មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | ✓ | | |

***សម្គាល់៖** (១) អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ (២) អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ និង (៣) មិនមែនជាអង្គភាពថវិកា។*

## IV. ការកំណត់រចនាសម្ព័ន្ធថវិកាសមិទ្ធកម្ម

### ក. ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅ

ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់សូចនាករសមិទ្ធកម្មនិងគោលដៅ ដើម្បីតាមដានវឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តកម្មវិធី អនុកម្មវិធី និងគោលបំណងគោលនយោបាយនីមួយៗដូចខាងក្រោម៖

| ការកំណត់សូចនាករសមិទ្ធកម្ម និង គោលដៅ នៃកម្មវិធី និង អនុកម្មវិធី | | | | | | | |
|---|---|---|---|---|---|---|---|
| សេចក្តីពណ៌នា | គម្រោងថវិកា ឆ្នាំ២០២៦ (លានរៀល) | គោលដៅសូចនាករសមិទ្ធកម្ម | | | | | |
| | | ឆ្នាំមុន* (២០២៤) | ឆ្នាំបច្ចុប្បន្ន (២០២៥) | ឆ្នាំគ្រោងថវិកា(២០២៦) | | ឆ្នាំគ្រោង ថវិកា (២០២៧) | ឆ្នាំគ្រោង ថវិកា (២០២៨) |
| | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្តូរ (ធៀបនឹងគោលដៅឆ្នាំ២០២៥) | | |
| គោលបំណងគោលនយោបាយ៖ "ធានាឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត" | | | | | | | |
| សរុបរួម | 4,256,248.1 | | | | | | |
| មន្ទីររាជធានី ខេត្ត (បីមុខងារ) | 1,944,014.9 | | | | | | |
| សរុបរួម (ចំណាយចរន្ត+ចំណាយមូលធន) | 2,312,233.2 | | | | | | |
| សរុបចំណាយចរន្ត | 2,232,233.2 | | | | | | |
| សរុបចំណាយមូលធន | 80,000.0 | | | | | | |
| **កម្មវិធីទី ១៖ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ** | 1,498,180.7 | | | | | | |
| ចំនួនសាលារៀនគំរូ | | 264 | 360 | 470 | | 500 | 800 |
| ភាគរយសិស្សថ្នាក់ទី ១២ ទទួលបាននិទ្ទេស A, B, និង C | | 25.7 | 24.3 | 25.5 | | 29 | 32 |

| ការកំណត់សូចនាករសមិទ្ធកម្ម និង គោលដៅ នៃកម្មវិធី និង អនុកម្មវិធី | | | | | | | |
|---|---|---|---|---|---|---|---|
| សេចក្តីពណ៌នា | គម្រោងថវិកាឆ្នាំ២០២៦ (លានរៀល) | គោលដៅសូចនាករសមិទ្ធកម្ម | | | | | |
| | | ឆ្នាំមុន* (២០២៤) | ឆ្នាំបច្ចុប្បន្ន (២០២៥) | ឆ្នាំគ្រោងថវិកា(២០២៦) | | ឆ្នាំគ្រោងថវិកា (២០២៧) | ឆ្នាំគ្រោងថវិកា (២០២៨) |
| | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្តូរ (ធៀបនឹងគោលដៅឆ្នាំ២០២៥) | | |
| **អនុកម្មវិធី ១.១៖ ការពង្រីកការអប់រំកុមារតូច** | 16,262.9 | | | | | | |
| ចំនួនសាលាមត្តេយ្យសិក្សាគំរូ | | 34 | 40 | 45 | | 50 | 55 |
| ភាគរយនៃកុមារចូលរៀននៅបឋមសិក្សាបានឆ្លងកាត់មត្តេយ្យសិក្សា | | 79.7 | 73.6 | 75.1 | | 76.6 | 78.1 |
| ប្រុស | | 78.2 | 57.5 | 59.5 | | 61.5 | 63.5 |
| ស្រី | | 81.2 | 91.1 | 92.1 | | 93.1 | 94.1 |
| **ច.ស.ក.ទី១ ៖ ការគាំពារនិងការអភិវឌ្ឍកុមារតូច** | | | | | | | |
| អត្រារួមនៃការសិក្សាអប់រំកុមារតូច (អាយុ ៣-៥ ឆ្នាំ) | | 43 | 41.1 | 43.1 | | 45.1 | 47.1 |
| ប្រុស | | 43.8 | 40 | 42 | | 44 | 46 |
| ស្រី | | 39.9 | 42.4 | 44.4 | | 46.4 | 48.4 |
| អត្រាចូលរៀនកុមារអាយុ ៥ឆ្នាំ | | 65.4 | 66.9 | 67.9 | | 69 | 70 |
| ប្រុស | | 70.9 | 66.2 | 67.2 | | 68.1 | 69 |
| ស្រី | | 71.9 | 67.7 | 68.8 | | 69.9 | 71 |
| ភាគរយសាលាមត្តេយ្យសិក្សារដ្ឋអនុវត្តកម្មវិធីអាហារតាមសាលារៀន | | 9.2 | 14.4 | 19.6 | | 24.8 | 30 |

| ការកំណត់សូចនាករសមិទ្ធកម្ម និង គោលដៅ នៃកម្មវិធី និង អនុកម្មវិធី | | | | | | | |
|---|---|---|---|---|---|---|---|
| សេចក្ដីពណ៌នា | គម្រោងថវិកា ឆ្នាំ២០២៦ (លានរៀល) | គោលដៅសូចនាករសមិទ្ធកម្ម | | | | | |
| | | ឆ្នាំមុន* (២០២៤) | ឆ្នាំបច្ចុប្បន្ន (២០២៥) | ឆ្នាំគ្រោងថវិកា(២០២៦) | | ឆ្នាំគ្រោងថវិកា (២០២៧) | ឆ្នាំគ្រោងថវិកា (២០២៨) |
| | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្តូរ (ធៀបនឹងគោលដៅឆ្នាំ២០២៥) | | |
| ចំនួនសាលាមត្តេយ្យសិក្សាសហគមន៍ដែលមានទីតាំងនៅតំបន់រោងចក្រ | | 6 | 12 | 18 | | 24 | 30 |
| ចំនួនមជ្ឈមណ្ឌលថែទាំកុមារតាមសហគមន៍ | | 13 | 17 | 22 | | 26 | 30 |
| ចំនួនសាលាមត្តេយ្យសិក្សាបានអនុវត្តកម្មវិធីសិក្សាថ្មី | | 20 | 115 | 197 | | 278 | 360 |
| **ច.ស.ក.ទី២ ៖ អភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីអនុវិស័យអប់រំកុមារតូច** | | | | | | | |
| ចំនួនគ្រូបង្រៀនអប់រំកុមារតូច និងអ្នកថែទាំបានទទួលការបណ្តុះបណ្តាលស្តីពីការអនុវត្តកម្មវិធីសិក្សា (មត្តេយ្យសិក្សាសហគមន៍ និងមជ្ឈមណ្ឌលថែទាំកុមារតាមសហគមន៍ក្នុងតំបន់រោងចក្រ) | | 52 | 77 | 101 | | 126 | 150 |
| **អនុកម្មវិធី ១.២៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា (នាយកដ្ឋានបឋមសិក្សា)** | **8,365.0** | | | | | | |
| ចំនួនសាលាបឋមសិក្សាសម្រេចបានស្តង់ដាសាលាបឋមសិក្សាគំរូ | | 90 | 200 | 300 | | 400 | 500 |

| ការកំណត់សូចនាករសមិទ្ធកម្ម និង គោលដៅ នៃកម្មវិធី និង អនុកម្មវិធី | | | | | | | |
|---|---|---|---|---|---|---|---|
| សេចក្ដីពណ៌នា | គម្រោងថវិកា ឆ្នាំ២០២៦ (លានរៀល) | គោលដៅសូចនាករសមិទ្ធកម្ម | | | | | |
| | | ឆ្នាំមុន* (២០២៤) | ឆ្នាំបច្ចុប្បន្ន (២០២៥) | ឆ្នាំគ្រោងថវិកា(២០២៦) | | ឆ្នាំគ្រោងថវិកា (២០២៧) | ឆ្នាំគ្រោងថវិកា (២០២៨) |
| | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្ដូរ (ធៀបនឹងគោលដៅឆ្នាំ២០២៥) | | |
| អត្រារួមនៃការសិក្សានៅបឋមសិក្សា | | 124.6 | 103.0 | 102.5 | | 102 | 101.5 |
| ប្រុស | | 126.8 | 104.2 | 103.7 | | 103.2 | 102.7 |
| ស្រី | | 122.4 | 101.7 | 101.3 | | 100.9 | 100.5 |
| អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | | 101.5 | 88 | 88.6 | | 89.2 | 89.8 |
| ប្រុស | | 99 | 86.1 | 86.6 | | 87.1 | 87.6 |
| ស្រី | | 104.1 | 90.6 | 91.1 | | 91.6 | 92.1 |
| **ច.ស.ក.ទី១ ៖ ការអភិវឌ្ឍការអប់រំបឋមសិក្សាដើម្បីធានាឱ្យការចូលរៀនមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន** | | | | | | | |
| អត្រាពិតចូលរៀនថ្មីនៅបឋមសិក្សា | | 97.2 | 92.4 | 93.7 | | 95 | 96.3 |
| ប្រុស | | 97.9 | 91.8 | 93.2 | | 94.5 | 95.9 |
| ស្រី | | 96.5 | 93 | 94.3 | | 95.5 | 96.8 |
| អត្រាគង់វង្សនៅបឋមសិក្សា | | 84.5 | 79.5 | 79.5 | | 81.5 | 82.5 |
| ប្រុស | | 79.6 | 80.7 | 80.7 | | 82.7 | 83.7 |
| ស្រី | | 89.8 | 78.3 | 78.3 | | 80.3 | 81.3 |
| ភាគរយកុមារចូលរៀនលើសអាយុ | | 12.7 | 11.2 | 9.7 | | 8.2 | 6.7 |
| ស្រី | | 11.4 | 9.9 | 8.4 | | 6.9 | 5.4 |
| អត្រាបោះបង់នៅបឋមសិក្សា | | 4.1 | 5.0 | 4.8 | | 4.6 | 4.4 |

| ការកំណត់សូចនាករសមិទ្ធកម្ម និង គោលដៅ នៃកម្មវិធី និង អនុកម្មវិធី | | | | | | | |
|---|---|---|---|---|---|---|---|
| សេចក្ដីពណ៌នា | គម្រោងថវិកា ឆ្នាំ២០២៦ (លានរៀល) | គោលដៅសូចនាករសមិទ្ធកម្ម | | | | | |
| | | ឆ្នាំមុន* (២០២៤) | ឆ្នាំបច្ចុប្បន្ន (២០២៥) | ឆ្នាំគ្រោងថវិកា(២០២៦) | | ឆ្នាំគ្រោងថវិកា (២០២៧) | ឆ្នាំគ្រោងថវិកា (២០២៨) |
| | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្ដូរ (ធៀបនឹងគោលដៅឆ្នាំ២០២៥) | | |
| ប្រុស | | 5.2 | 4.8 | 4.6 | | 4.4 | 4.2 |
| ស្រី | | 2.9 | 5.3 | 5.1 | | 4.9 | 4.7 |
| អត្រាត្រួតថ្នាក់នៅបឋមសិក្សា | | 5.4 | 5.6 | 5.5 | | 5.4 | 5.3 |
| ប្រុស | | 6.9 | 7.1 | 7 | | 6.9 | 6.8 |
| ស្រី | | 3.9 | 3.9 | 3.8 | | 3.7 | 3.6 |
| ចំនួនសិស្សក្រីក្រនៅបឋមសិក្សាទទួលបានអាហារូបករណ៍ | | 148,979 | 148,957 | 148,957 | | 158,957 | 158,957 |
| ចំនួនសាលាបឋមសិក្សាបានអនុវត្តកម្មវិធីអាហារតាមសាលារៀន | | 553 | 686 | 816 | | 816 | 960 |
| ភាគរយសាលារៀនដែលអនុវត្តអំណាន និង គណិតវិទ្យាថ្នាក់ដំបូង (EGL) | | | | | | | |
| ភាសាខ្មែរថ្នាក់ទី១ | | 100 | 85.4 | 90.3 | | 95.1 | 100 |
| គណិតវិទ្យាថ្នាក់ទី១ | | 42.9 | 48.5 | 65.7 | | 82.8 | 100 |
| ភាសាខ្មែរថ្នាក់ទី២ | | 86 | 75.8 | 83.9 | | 91.9 | 100 |
| គណិតវិទ្យាថ្នាក់ទី២ | | 31.3 | 40.1 | 53.4 | | 66.7 | 80 |
| ភាសាខ្មែរថ្នាក់ទី៣ | | 14.9 | 15.4 | 26.9 | | 38.5 | 50 |
| គណិតវិទ្យាថ្នាក់ទី៣ | | 6.7 | 7.5 | 15 | | 22.5 | 30 |

| ការកំណត់សូចនាករសមិទ្ធកម្ម និង គោលដៅ នៃកម្មវិធី និង អនុកម្មវិធី | | | | | | | |
|---|---|---|---|---|---|---|---|
| **សេចក្ដីពណ៌នា** | គម្រោងថវិកា ឆ្នាំ២០២៦ (លានរៀល) | គោលដៅសូចនាករសមិទ្ធកម្ម | | | | | |
| | | ឆ្នាំមុន* (២០២៤) | ឆ្នាំបច្ចុប្បន្ន (២០២៥) | ឆ្នាំគ្រោងថវិកា(២០២៦) | | ឆ្នាំគ្រោងថវិកា (២០២៧) | ឆ្នាំគ្រោងថវិកា (២០២៨) |
| | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្ដូរ (ធៀបនឹងគោលដៅឆ្នាំ២០២៥) | | |
| ចំនួនសាលារៀនអនុវត្តសកម្មភាពក្រៅម៉ោងសិក្សានៅថ្នាក់ទី៤ ដល់ទី៦ | | 175 | 90 | 200 | | 200 | 370 |
| ចំនួនសាលាបឋមសិក្សាអនុវត្តកម្មវិធីសិក្សាពេញមួយថ្ងៃ | | 47<br>13ខេត្ត | 80 | 80 | | 80 | 80 |
| ចំនួនសាលាបឋមសិក្សាជំនាន់ថ្មី | | 4 | 4 | 4 | | 60 | 72.5 |
| ភាគរយសាលាបឋមសិក្សាអនុវត្តយ៉ាងពេញលេញនូវក្របខ័ណ្ឌកម្មវិធីសិក្សា | | N/A | 47.5 | 60 | | 60 | 60 |
| ភាគរយសាលាបឋមសិក្សាដែលមានគណៈកម្មការគ្រប់គ្រងសាលារៀនសកម្មតាមខេត្ត/ស្រុក | | N/A | 20 | 30 | | 30 | 40 |
| **ច.ស.ក.ទី២ ៖ ការអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំបឋមសិក្សា** | | | | | | | |
| ចំនួនសាលាបឋមសិក្សាបានទទួលការណែនាំ និងបង្វឹកស្ដីពីស្ដង់ដាសាលារៀនគំរូ | | 166 | 368 | 645 | | 923 | 12,000 |
| ចំនួនគ្រូបង្រៀនបានទទួលការបណ្ដុះបណ្ដាលស្ដីពីអំណាន និងគណិតវិទ្យាថ្នាក់ដំបូង (ថ្នាក់ទី ១-៣) | | | | | | | |

| ការកំណត់សូចនាករសមិទ្ធកម្ម និង គោលដៅ នៃកម្មវិធី និង អនុកម្មវិធី | | | | | | | |
|---|---|---|---|---|---|---|---|
| សេចក្តីពណ៌នា | គម្រោងថវិកា ឆ្នាំ២០២៦ (លានរៀល) | គោលដៅសូចនាករសមិទ្ធកម្ម | | | | | |
| | | ឆ្នាំមុន* (២០២៤) | ឆ្នាំបច្ចុប្បន្ន (២០២៥) | ឆ្នាំគ្រោងថវិកា(២០២៦) | | ឆ្នាំគ្រោងថវិកា (២០២៧) | ឆ្នាំគ្រោងថវិកា (២០២៨) |
| | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្តូរ (ធៀបនឹងគោលដៅឆ្នាំ២០២៥) | | |
| អំណានថ្នាក់ដំបូង | | 24,744 | 22,000 | 25,000 | | 28,000 | 30,000 |
| គណិតវិទ្យាថ្នាក់ដំបូង | | 8,332 | 9,000 | 12,000 | | 15,000 | 20,000 |
| **អនុកម្មវិធី ១.៣៖ ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ)** | **8,777.3** | | | | | | |
| ចំនួនសាលាមធ្យមសិក្សាចំណេះទូទៅសម្រេចបានស្តង់ដាសាលារៀនមធ្យមសិក្សាគំរូ | | 135 | 168 | 214 | | 256 | 292 |
| មធ្យមសិក្សាបឋមភូមិគំរូ | | 20 | 65 | 100 | | 140 | 175 |
| មធ្យមសិក្សាទុតិយភូមិគំរូ | | 115 | 103 | 114 | | 116 | 117 |
| អត្រារួមនៃការសិក្សានៅមធ្យមសិក្សា | | | | | | | |
| មធ្យមសិក្សាបឋមភូមិ | | 66.4 | 67.4 | 68.4 | | 69.4 | 70.4 |
| មធ្យមសិក្សាទុតិយភូមិ | | 45.8 | 46.3 | 48.8 | | 50.3 | 51.8 |
| អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សា | | | | | | | |
| មធ្យមសិក្សាបឋមភូមិ | | 61.2 | 62.2 | 63.2 | | 64.2 | 65.4 |
| មធ្យមសិក្សាទុតិយភូមិ | | 39.9 | 40.9 | 41.9 | | 42.9 | 43.9 |

| ការកំណត់សូចនាករសមិទ្ធកម្ម និង គោលដៅ នៃកម្មវិធី និង អនុកម្មវិធី | | | | | | | |
|---|---|---|---|---|---|---|---|
| **សេចក្តីពណ៌នា** | គម្រោងថវិកា ឆ្នាំ២០២៦ (លានរៀល) | **គោលដៅសូចនាករសមិទ្ធកម្ម** | | | | | |
| | | ឆ្នាំមុន* (២០២៤) | ឆ្នាំបច្ចុប្បន្ន (២០២៥) | ឆ្នាំគម្រោងថវិកា(២០២៦) | | ឆ្នាំគម្រោងថវិកា (២០២៧) | ឆ្នាំគម្រោងថវិកា (២០២៨) |
| | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្តូរ (ធៀបនឹងគោលដៅឆ្នាំ២០២៥) | | |
| ប.ស.ក.ទី១ ៖ បង្កើនការចូលរៀននៅមធ្យមសិក្សា និងជួយសិស្សរៀនមានសមត្ថភាពបញ្ញាល្អប្រសើរ និងរៀនចប់នៅមធ្យមសិក្សា | | | | | | | |
| អត្រាឆ្លងភូមិសិក្សាពី | | | | | | | |
| បឋមសិក្សា ទៅមធ្យមសិក្សាបឋមភូមិ | | 85 | 86 | 87.5 | | 85 | 85 |
| មធ្យមសិក្សាបឋមភូមិ ទៅមធ្យមសិក្សាទុតិយភូមិ | | 79.1 | 80.6 | 82 | | 88.7 | 90 |
| អត្រាគង់វង្ស | | | | | | | |
| មធ្យមសិក្សាបឋមភូមិ | | 54.6 | 55.6 | 56.6 | | 57.6 | 58.6 |
| មធ្យមសិក្សាទុតិយភូមិ | | 35.1 | 36.1 | 37.1 | | 38.1 | 39.1 |
| អត្រាបោះបង់នៅមធ្យមសិក្សា | | | | | | | |
| មធ្យមសិក្សាបឋមភូមិ | | 15.2 | 15 | 14.8 | | 14.6 | 14.4 |
| មធ្យមសិក្សាទុតិយភូមិ | | 13.5 | 13.3 | 13.1 | | 12.9 | 12.7 |
| អត្រាត្រួតថ្នាក់នៅមធ្យមសិក្សា | | | | | | | |
| មធ្យមសិក្សាបឋមភូមិ | | 3.4 | 3.2 | 3 | | 2.8 | 2.6 |
| មធ្យមសិក្សាទុតិយភូមិ | | 1.5 | 1.3 | 1.1 | | 0.9 | 0.7 |
| ចំនួនសិស្សក្រីក្រនៅមធ្យមសិក្សាបឋមភូមិទទួលបានអាហារូបករណ៍ | | 119,961 | 119,961 | 119,961 | | 119,961 | 119,961 |

| ការកំណត់សូចនាករសមិទ្ធកម្ម និង គោលដៅ នៃកម្មវិធី និង អនុកម្មវិធី | | | | | | | |
|---|---|---|---|---|---|---|---|
| សេចក្ដីពណ៌នា | គម្រោងថវិកាឆ្នាំ២០២៦ (លានរៀល) | គោលដៅសូចនាករសមិទ្ធកម្ម | | | | | |
| | | ឆ្នាំមុន* (២០២៤) | ឆ្នាំបច្ចុប្បន្ន (២០២៥) | ឆ្នាំគ្រោងថវិកា(២០២៦) | | ឆ្នាំគ្រោងថវិកា (២០២៧) | ឆ្នាំគ្រោងថវិកា (២០២៨) |
| | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្ដូរ (ធៀបនឹងគោលដៅឆ្នាំ២០២៥) | | |
| ចំនួនសិស្សក្រីក្រនៅមធ្យមសិក្សាទុតិយភូមិទទួលបានអាហារូបករណ៍ | | 13,117 | 13,117 | 13,117 | | 13,117 | 13,117 |
| ចំនួនសាលាមធ្យមសិក្សាអនុវត្តសកម្មភាពក្រៅម៉ោងសិក្សា | | 20 | 30 | 55 | | 75 | 100 |
| ចំនួនសាលារៀនជំនាន់ថ្មី | | 9 | 11 | 13 | | 15 | 16 |
| **ច.ស.ក.ទី២ ៖ ការលើកកម្ពស់ការងារគ្រប់គ្រងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** | | | | | | | |
| ចំនួនសាលារៀនដែលមានគណៈកម្មការគ្រប់គ្រងសាលារៀនដំណើរការសកម្ម | | 856 | 600 | 1,212 | | 1,576 | 1,923 |
